ឧបសៅសង្ហា

# ព្រះបាទអង្គដួង (១៨៤១-១៨៦០)



បដិមាករ សន្តវង្ស នៃ ព្រះអង្គដួង

# ពិនិត្យឡើងវិញនូវព្រឹត្តិការណ៍សំខាន់ៗមាននៅក្នុងប្រវត្តិសាស្រ្តខ្មែរ

**សង្ខេប សម្រួល ដកស្រង់ ពី ឯកសារ លោក អេង សុត និង អធិប្បាយ ជា មតិផ្ទាល់**

## មាតិការឿង


**សេចក្តីផ្តើម** ........ 2
**ស្ថានភាព នៃ ការឡើងគ្រងរាជសម្បត្តិរបស់ ព្រះអង្គដួង** 3
**ការរៀបចំប្រទេស** ........ 23
**ព្រឹត្តិការណ៍សំខាន់ៗ នៅក្នុងព្រះនគរ** ........ 40
**អត្ថាធិប្បាយ ជា អត្តនោម័តិ** ........ 43
**ឯកសារ ភ្ជាប់** ........ 56

# សេចក្ដីផ្ដើម

នៅឆ្នាំ ១៤៣២ ព្រះបាទ ពញាយ៉ាត បានចាកចេញពីមហានគរ មកតាំងរាជធានី នៅស្រុកស្រីសន្ធ ដែលស្ថិតនៅ រវាង ទន្លេសាប នឹង ទន្លេតូច ព្រោះទ្រង់យល់ឃើញថាមហានគរ នៅជាប់ព្រំប្រទល់ ខ្មែរ-សៀម ដែលនាំឲ សៀមងាយលើកទ័ពមកវាយរាជធានីខ្មែរ។ ក្រោយរប្តិមក ព្រះអង្គ ក៏លើករាជធានី ពី ស្រុកស្រីសន្ធ មកតាំងទីថ្មីនៅក្បែរ ទន្លេបួនមុខ ប្រហែលគ្នានឹង ក្រុងភ្នំពេញបច្ចុប្បន្ន។ ក្រោយមក ព្រះបាទ អង្គចន្ទ ឬ មហាចន្ទរាជា (១៥១៦-១៥៦៨) ដែលខ្មែរទុកជា មហាក្សត្រ ឈ្នះសៀម បានប្តូររាជធានី ពី ទន្លេបួនមុខ មកតាំងទីថ្មីនៅ លង្វែក ក្បែរស្រុក ឆ្នុកទ្រូ។ នៅក្នុង រជ្ជកាល ព្រះចន្ទរាជា និង ព្រះបាទ បរម្ករាជា ជា ព្រះរាជបុត្រ ស្រុកខ្មែរនៅ ថ្កុំថ្កើង នៅឡើយ។

តែមកដល់ឆ្នាំ ១៥៩៤ សៀមបានវាយបែកបន្ទាយលង្វែក ហើយចាប់ពីពេលនោះមក ស្រុកខ្មែរ បានធ្លាក់អន់ថយឥទ្ធិពលយ៉ាងខ្លាំង។ ត្រូវដឹកថា សៀមធ្លាប់វាយលុកស្រុកខ្មែរ បីលើកមកហើយ គឺនៅ ឆ្នាំ ១៤៣២, ១៤៧៧ និង ១៥១៥។

នៅពាក់កណ្ដាលសតវត្សទី១៧ ពួកយួន (ដៃ វៀត) បានចូលមកវាយលុកស្រុកខ្មែរ ក្រោមការដឹកនាំ នៃ ពួក

ង្វៀង នៃ ទីក្រុងហ្វៃ យកដីខ្មែរមួយចំនួន ដាក់បញ្ចូលទៅក្នុងនគរយួន។ នៅសតវត្សទី១៩ មានសង្គ្រាម យួន នឹង សៀម ដណ្តើម ស្រុកខ្មែរ ដាក់ជាប្រទេសចំណុះ។ បន្ទាប់មក ប្រទេសទាំងពីរ គេ បញ្ឈប់សង្គ្រាម តាមការព្រមព្រៀងរួមមួយ ទុកស្រុកខ្មែរ ជា សហជីវិតរាជ្យ របស់សៀម-យួន ទទួលស្គាល់ ព្រះអង្គដួង ជា ស្តេចខ្មែរ។

យើងលើកយករជ្ជកាលព្រះបាទអង្គដួង មកសរសេរ ព្រោះព្រះមហាក្សត្រអង្គនេះ ត្រូវរបបរាជានិយម តាំងតែពីដំបូង នៃ ជំនាន់អាណាព្យាបាលបារាំង នៅស្រុកខ្មែរ ទុកជា ស្ថាបទក្សត្រ នៃសន្តតិវង្សថ្មី របស់រាជានិយមខ្មែរ។ ព្រះបាទអង្គដួង ទ្រង់បានឡើង សោយរាជសម្បត្តិ នៅថ្ងៃអង្គារ ខែ កុម្ភៈ ឆ្នាំ ១៨៤៧ វេលា ម៉ោង៧ព្រឹក ព្រះអង្គមាន ព្រះជន្ម៥២ឆ្នាំ ត្រូវជា ព្រះរាជបុត្រពៅ ព្រះបាទអង្គអេង។ ព្រះអង្គ សោយរាជសម្បត្តិ តពី ព្រះអង្គម៉ីក្សត្រីដែលត្រូវជា ព្រះភាគិនេយ្យា (ក្មួយស្រី) របស់ព្រះអង្គ ស្តេចគង់ក្នុង ព្រះបរមរាជវាំង ឧដុង្គព្ជ័យ។

## ស្ថានភាព នៃ ការឡើងគ្រងរាជសម្បត្តិរបស់ ព្រះអង្គដួង

ចាប់ពី សតវត្សទី១៥មក រាជានិយមខ្មែរ ជួបប្រទះ នូវវិបត្តិ នៃ ឧត្តរាធិការ បង្កើតជា ជម្លោះអាវុធ រវាង អភិមនិក នៃ រាជបល្ល័ង្ក។ ស្តេច យុទ្ធការី ទាំងនោះ សូមជំនួយ

ពីបរទេស ដើម្បី ច្បាំង រក្សា ឬ ទាមទារ រាជបល្ល័ង នាំឲ ប្រជាជាតិ ខាតបង់ប្រយោជន៏ជាតិជាច្រើន។

សង្គ្រាម ជាមួយ សៀម ច្រើនគ្រា (ឆ្នាំ ១៤៣២, ១៤៧៧, ១៥១៥, ១៥៩៤) រំគាយ កម្លាំងជាតិ និង រាជានិយមខ្មែរ។ បន្ទាប់មក នៅ សតវត្សទី១៧ នៅក្នុង រជ្ជកាល ព្រះបាទ ជ័យជេដ្ឋា ទី២ (ទ្រង់បានលើករាជធានី ពីក្រុងលង្វែក មកតាំងនៅទីក្រុង ឧដុង្គ) យួន ក៏ចាប់ផ្ដើម លុកចូល មកក្នុងទឹកដីស្រុកខ្មែរ តាមការអនុញ្ញាតពី ព្រះរាជាខ្មែរ ហើយកាត់កាប់ ខេត្តព្រៃនគរ។ ក្រោយពីព្រះអង្គ សោយ ព្រះទិវង្គត មានការធ្វើឃាតគ្នា បន្តបន្ទាប់ នៅក្នុងព្រះ រាជវង្សានុវង្ស ដើម្បី រាជបល្ល័ង និង ការប្ដូរសាសនា របស់ ព្រះអង្គចន្ទ ហៅ ព្រះសត្ថា (១៦៥៣-១៦៥៦) យក សាសនា អ៊ីស្លាម ជារាជជំនឿ ព្រោះតែ ទ្រង់ស្រឡាញ់ នាង សារ៉ះ បុប្ផា ជាកូនចាម និង ជឿ សង្គ្រាជចាម ថា សាសនាមហា ហ្ម៉ែត អាចទទួលជួយទាំងអស់ ដល់ជនទាំងឡាយ ដែល បានចូលសាសនាគាប់គុណ ដូចមានសម្ដែងក្នុងព្រះគម្ពី ថា : បើសិស្សានុសិស្សឯណា ចូលលូក្នុងព្រះវិហារហើយ បានរួមសម្ពន្ធលើមាតា ម្ដាយមីង ម្ដាយធំនោះ ទោះបីម្ដា យមីង ម្ដាយធំ ខាងខ្លួនក្ដី ខាងភរិយាក្ដី លោកសន្មតថា សិស្សានុសិស្សទាំងនោះ នឹងរងដួងកែវកំណើតឃើញវិញ ជាប្រាកដ។ ថាបើសិស្សានុសិស្សទាំងនោះ ធ្វើបាបសម្លាប់

អ្វីៗ មួយរយដងក្តី មួយពាន់ដងក្តី អំពើបាបនោះ នឹងអន្ទោលតាមពាំទាន់ ពុំជិតជិតដល់ខ្លួនឡើយ។ ទស្សនៈនេះខុសពី ព្រះ សង្ឃរាជា ពន្យល់ថ្វាយព្រះពរព្រះអង្គថា : បុណ្យនិងបាប មានតែដោយចំណែកប្លែកពីគ្នា។ ថាបើទ្រង់បានធ្វើបុណ្យច្រើនតទៅ នឹងសោយសុខជាមុន បើទ្រង់បានធ្វើបាបច្រើន ទ្រង់ទៅសោយទុក្ខ ជាមុនប៉ុណ្ណោះ គ្មានក្នុងព្រះពុទ្ធប្បញ្ញាតិ ឬ ពុទ្ធានុញ្ញាត ឲកាត់កងសងគ្នានោះឡើយ។

ត្រូវដឹងថា ដើម្បី រាជបល្ល័ង ព្រះសត្ថា ទ្រង់បាន ធ្វើគតព្រះបិតុលា និង ព្រះជេដ្ឋា[1] ព្រះនាម ព្រះអង្គនន្ទ ជា ស្តេចគ្រងរាជ្យផង (១៦៥០-១៦៥៣) ដែលនាំឲទ្រង់មាន វិបត្តិចិត្តខ្លាំងណាស់ ចង់លាងបាបកម្ម ដោយយល់ឃើញថាសាសនាអ៊ីស្លាម អាចផ្តល់ នូវលទ្ធភាពនេះ និង ស្រឡាញ់ងប់ នាងសារ៉ះបុប្ផា ជាស្នំឯកផង ព្រះអង្គ ក៏សម្រេចចិត្តចូលសាសន៏ចាមតែម្តង។ តែ ព្រះរាជហឫទ័យ នេះ ធ្វើឲមាន ឧទ្ទាមកម្ម ប្រឆាំងនឹងព្រះអង្គ ដឹកនាំដោយ ព្រះអង្គសូ និង តន់ ដែលជា បុត្រា សម្តេចព្រះឱទ័យ ដែរដោយមានជំនួយពី មហារាជជននី ចូវ[2] (បុត្រី របស់ព្រះ

---

[1] ព្រះជេដ្ឋា ត្រូវជាបងជីដូនមួយរបស់ព្រះអង្គ ហើយជាបុត្រាព្រះបិតុលា ព្រះនាម សម្តេចព្រះឱទ័យ ជាព្រះមហាឧភយោរាជ។

[2] មហារាជជននី ចូវ ទោះបី ព្រះស្វាមី និង បុត្រាទោល ព្រះនាម ព្រះស្រីធម្មរាជា ឬ ពញាតូ (១៦៣៦-១៦៤០) សុគត ចោលព្រះអង្គក៏ដោយ តែព្រះអង្គនៅមានឥទ្ធិពលខ្លាំងណាស់នៅស្រុកខ្មែរ។ ព្រះអង្គ គង់នៅ ទីក្រុងភ្នំពេញ

*(note de bas de page - suite)*

ចៅក្រុងហ្វេ) ជា អគ្គមហេសី របស់មកតកស្តេច ជ័យជេដ្ឋា ទី២ បានស្នើដល់ព្រះបិតា សូមជំនួយទ័ពយួន មកជួយច្បាំងនឹងព្រះរាជាខ្មែរ។ ទ័ពយួនច្បាំងឈ្នះទ័ពខ្មែរ ចាប់ស្តេចខ្មែរយកទៅស្រុកយួន។ មិនតែប៉ុណ្ណោះ មេទ័ពយួនមានគោលបំណង ចាប់ ព្រះអង្គ សូ និង តន់ ថែមទៀត តែ ព្រះអង្គទាំងពីរ ដឹងខ្លួនទាន់ បាននាំគ្នាចាកចេញពីក្រុងភ្នំពេញ នាំយក ព្រះអង្គចូវ តាមជាមួយ ទៅបញ្ចុះបញ្ចូល ទ័ពហ្លួងសល់នៅការពារ ក្រុងឧដុង្គ ដើម្បី រួមគ្នាវាយទ័ពយួនវិញ រហូតទទួលបានជ័យជំនះ។

ចាប់ពីតវត្សទី១៨ ស្រុកខ្មែរ ប្រឈរមុខនឹងការវាយលុយពីប្រទេសសៀម និង យួន។ ត្រូវដឹងថា សៀម ឈប់មានសង្គ្រាមនឹងប្រទេសភូមាកាលណា ក៏ចាប់បន្ត ធ្វើសកកម្មភាព ឈ្លានពានទឹកដីខ្មែរ ដូចយ៉ាង នៅឆ្នាំ ១៧៩៤ យកបានខេត្ត បាត់ដំបង ដាក់ជាទឹកដីចំណុះសៀម។ នៅពាក់កណ្តាល សតវត្សទី១៨ មាន សង្គ្រាម ដណ្តើមរាជសម្បត្តិ រវាងស្តេចខ្មែរ : ព្រះអង្គ ឱទ័យទី២ (១៧៥៨-១៧៧៥) ដែលមានយួន ជាអ្នកប្រដុងប្រជា នឹង ព្រះអង្គ

មានសេនាយួន ៥០០នាក់ មកពីក្រុងហ្វេ ជាកងការពារព្រះអង្គ។ ព្រះអង្គចូវ តែងតែ ធ្វើអន្តរាគមន៍ ចំពោះ ព្រះមហាក្សត្រខ្មែរទាំងឡាយ ដែលចង់ទាមទារ យកខេត្ត ព្រៃនគរពីយួនវិញ ដោយលើកហេតុផលផ្សេងៗថាសូមឲយួនបន្តរស់នៅសិនចុះ ហើយយកជីវិតប្តូរថា មិនឲដីខ្មែរនេះ បាត់នោះឡើយ។

នន់ ឬ រាមាធិបតី (១៧៧៥-១៧៧៩) ដែលមានសៀម ជាអ្នកគាំពាររក្សា។

ព្រះអង្គចន្ទទី២ (១៨០៦-១៨៣៤) ជាបុត្រាច្បង ព្រះអង្គអេង (១៧៩៤-១៨០៦) ត្រូវស្តេចសៀម ថ្វាយរាជសម្បត្តិ តពីព្រះបិតា។ ត្រូវដឹងថា តាំងពី រជ្ជកាល ព្រះអង្គអេង ស្រុកខ្មែរ ជាស្រុកចំណុះសៀម ដឹកនាំដោយ មន្ត្រីខ្មែរម្នាក់ មានងារជា សម្តេចចៅហ្វា (ប៉ុក) ស្មោះត្រង់នឹងព្រះចៅសៀមណាស់ ព្រះនាម ព្រះពុទ្ធយ៉តហ្វាចូឡាលោក។ នៅដើមរជ្ជកាល ព្រះអង្គចន្ទទី២ សម្តេចចៅហ្វាប៉ុក បានបញ្ជូនទ័ពខ្មែរចំនួន មួយម៉ឺននាក់ ទៅជួយសៀម ច្បាំងនឹងភូមា។ ស្រុកខ្មែរ នៅពេលនោះ ក៏ជួយច្បាំង ព្រះចៅយួននឹងឧទ្ទាមកម្ម (យួនកៃសឺន) នៅស្រុកយួន។ មេទ័ពខ្មែរឈ្មោះ ព្រាំ ពេលជួយច្បាំងយួនឈ្នះ ពេលត្រឡប់មកស្រុកខ្មែរ ក៏មានចិត្តអាងខ្លួន ក៏ពុំមានសេចក្តី ទៅជំរាបសម្តេចចៅហ្វាប៉ុក ដល់ម្តង ហើយ ក៏មិនដែលចូលប្រជុំនុំប្រឹក្សាផែនដី ជាមួយ ដែរ។ ប៉ុក បញ្ជា ឲចាប់ ព្រាំ ធ្វើទោសជាទម្ងន់ពុំប្រណី ហើយបញ្ជូនទៅស្រុកសៀម។ ក្នុងជន្មាយុ ៦៥ឆ្នាំ សម្តេចចៅហ្វាប៉ុក ទទួល អនិច្ចកម្ម នៅស្រុកសៀមដោយជម្ងឺ។ ក្រោយពីមរណភាព សម្តេចចៅហ្វាប៉ុក ព្រះចៅសៀម បានអញ្ជើញព្រះអង្គចន្ទ ឡើងសោយរាជសម្បត្តិ គ្រងក្រុងកម្ពុជាធិបតី។ នៅឆ្នាំ ១៨០៦ ព្រះចៅ

សៀម អនុញ្ញាត ឲព្រះអង្គចន្ទ វិលត្រឡប់មកគ្រប់គ្រង បុរីឧដុង្គព្ជជ័យ។

ដឹងដំណឹងថា ព្រះអង្គចន្ទ គង់នៅ ក្រុងឧដុង្គ ព្រះចៅយួន ព្រះនាម យ៉ាឡុង[3] (១៧៧៩-១៨២០) ត្រាស់ប្រើរាជទូតយួន ឲនាំ ត្រាមាស៤ជ្រុង រូបគោ ទម្ងន់៧ណែនប្រាក់ និង រាស្រ្តយួន ៥០០ នាក់ ជាចំណងព្រះហស្ត មកថ្វាយព្រះចៅខ្មែរ។

## អន្តរាគមន៍យួននៅស្រុកខ្មែរ

នៅឆ្នាំ ១៨១១ កើតបុព្វនិមិត្ត ឃើញផ្កាយដុះកន្ទុយចាក់ទៅទិសពាយ័ព្យ ដែលនាំឲព្រះអង្គស្ងួន (ព្រះអនុជ របស់ហ្លួងចន្ទ) ជាមហាឧភយោរាជ កើតបណ្ដាលក្នុងព្រះទ័យ

[3] អធិរាជយួននេះឯង ទទួលចុះចូលប្រទេសចិន ហើយ ត្រូវអភិសេកនៅហាណូយក្នុងឆ្នាំ ១៨០៤។ អធិរាជចិន នៅសម័យនោះ នាម គាគីង ដាក់ឈ្មោះអោយប្រទេសយួនថា ‹វៀត-ណាម› ដែលប្រមូលផ្តុំ តុងកឹង (បាក់គី) អណ្ណាម (ទ្រុងគី) និង កូសាំងស៊ីន (ណាមគី)។ ស្ដេច យ៉ាឡុង ជា ត្រកូលង្វៀង ដែលជាត្រកូល ស្ដេចត្រាញ់យួនខាងត្បូង។ ពួកនេះ មុនដំបូងពង្រីករាជាណាចក្រ របស់ខ្លួន លើទឹកដីចាម បន្ទាប់មកបានមកពីខ្មែរ គឺទឹកដីកម្ពុជាក្រោម។ ពួកង្វៀងនេះ តាំងរាជធានី នៅហ្វេ។ នៅអណ្ណាមខាងជើង ស្ដេចគ្រងរាជ្យ គឺ រាជវង្ស ទ្រិញ។ រាជវង្សនេះ សោយរាជ្យ ជាមួយស្ដេចត្រាញ់ត្រកូល ទ្រិញ។ ពួកនេះ ចេះតែ មកវាយស្ដេចត្រាញ់ត្រកូលង្វៀងនៅអណ្ណាមខាងត្បូង។ គឺ ស្ដេច យ៉ាឡុង នេះឯង ជាអ្នកបង្រួបបង្រួមអណ្ណាមទាំងពីរអោយចូលគ្នា មានឈ្មោះថា វៀត-ណាម្មេលសព្វថ្ងៃសរសេរជា វៀតណាម។ នៅឆ្នាំ ១៤៨០ នគរដាយវៀត មានកើតចម្បាំងដណ្ដើមរាជគ្នា បែកជា អណ្ណាមពីរ ខាងត្បូង និង ខាងជើង។ នៅសម័យនោះ មេក្រុមនានាកើតឡើង តាំងខ្លួនជាស្ដេចសោយរាជ្យ មានឈ្មោះ ក្នុងភាសាយួន ថា ‹ចៅ›។ តែមានស្ដេចធំបំផុត នៅក្នុងរាជាណាចក្រ មានឈ្មោះថា ‹វ៉ា› តែជាស្ដេចជានិមិត្តរូប តែប៉ុណ្ណោះ។ ឯស្ដេចត្រាញ់ ‹ចៅ› វិញ ជាអ្នកកាន់កាប់កងទ័ព ដកហូតពន្ធដារអាករ ចែកចាយបុណ្យសក្តិ គឺថា ជាអ្នកចាត់ចែង គ្រប់គ្រងកិច្ចការ ទឹកដីរបស់ខ្លួនរៀងខ្លួន។

មិនចង់គង់ក្នុងក្រុងជាមួយព្រះរៀម ក៏លួចនាំបណ្តាលរាស្ត្រជាខ្ញុំរាជការ របស់ព្រះអង្គ ចេញពីក្រុងទាំងយប់ ទៅរស់នៅ ក្នុងខេត្តពោធិសាត់ ដោយមាន ចៅហ្វាយខេត្តឈ្មោះ ប៉ុក គាំពាររក្សាព្រះអង្គ។ ព្រះអង្គចន្ទ ទ្រង់ជ្រាបហើយ ត្រាស់ប្រើព្រះរាជាគណៈ ឲទៅអញ្ជើញព្រះអនុជយាងមកវិញ តែស្តេចមិនព្រមមក។ ដោយបារម្ភ ខ្លាចព្រះអនុជ ក្បត់នឹងព្រះអង្គ ព្រះរាជា ចាត់ឧកញ៉ា អុង ឲទៅសុំទ័ពស្តេចយួន យ៉ាឡុង។ ព្រះចៅយួន ក៏ប្រញាប់បញ្ជូនទ័ពយួន ៥០០ នាក់ មកបោះទ័ពនៅកោះចិន ចាំគាំពាររក្សា ព្រះរាជាខ្មែរ។ រីឯ ព្រះចៅសៀម វិញ ពេលដឹងដំណឹងថា ព្រះអង្គចន្ទ ទៅសុំទ័ពយួន មកការពារព្រះអង្គស្តេចក៏ចាត់មេទ័ព ឲលើកទ័ពសៀមមកស្រុកខ្មែរ ជួបនឹងព្រះមហាឧភយោរាជ នៅខេត្តពោធិសាត់។ មេទ័ពសៀម ចូលក្រាបថ្វាយបង្គំព្រះអង្គស្ងួន ហើយក្រាបទូលថាព្រះចៅសៀម ចាត់ខ្លួនឲមកជួយ កុំឲព្រះអង្គព្រួយព្រះទ័យ ខ្លាចទ័ពយួនឡើយ។ ដោយមានទ័ពសៀម ជាអ្នកការពារ ព្រះអង្គស្ងួន ត្រាស់ប្រើមន្ត្រីព្រះអង្គ ឲក្រាបទូលព្រះអង្គចន្ទ សុំយកខេត្ត ក្រគរ និង ខ្លុងក្រង ជា ចំណែកដាច់មុខ របស់ទ្រង់។ ព្រះអង្គចន្ទ យល់ព្រមតាមសំណើររបស់ព្រះអនុជទាំងអស់។ បន្ទាប់មក ព្រះចៅសៀម ត្រាស់បញ្ជាឲមេទ័ពសៀម នាំសេនាទាហាន ៥ពាន់នាក់ មកបោះទ័ពនៅខែត្រ បាត់ដំបង មួយកង ផ្លូវស្ទឹងត្រែង

មួយកង។ ព្រះអង្គចន្ទ ដឹងដំណឹងនេះ ក៏រៀបចំខ្សែក្រវាត់ បោះទ័ពឈរប្រចាំល្បាតនៅ ខែត្រ រលាប្អៀរ កំពង់ឆ្នាំង នឹងគ្រប់ផ្លូវទឹក មកកាន់ក្រុងឧដុង្គ។ មេទ័ពយួន ចាត់សេនាមួយក្រុម ទៅស៊ើបយកដំណឹងនៅស្រុកបាត់ដំបង។ តែកងឈ្លបយួន ត្រូវបាន ទ័ពព្រះអង្គស្ងួន ចាប់ខ្លួនបាន។ ព្រះអង្គចន្ទ ស្ដេចព្រួយព្រះទ័យណាស់ ក៏ស្ដេចចេញពីក្រុងឧដុង្គ មកប្រថាប់នៅកំពង់ពោធិតូច។ នៅឆ្នាំ ១៨១២ ទ័ពសៀម ចាប់ផ្ដើម វាយសម្រុក មូលដ្ឋានទ័ពហ្លួង តាមផ្លូវទឹក។ ព្រះស្រីជ័យជេដ្ឋ (អង្គអិម) និង ព្រះអង្គដួង[4] ដែលជាអនុជ របស់ហ្លួងចន្ទ ក៏លួចរត់ចេញពីទ័ពព្រះរៀម ទៅស្រុកសៀម។ កាល ហ្លួនចន្ទ ជ្រាបថា ព្រះអនុជទាំងពីរ វេះរត់ចោលព្រះអង្គហើយ ទ្រង់ ឲចេញទីនាំនាវា សំដៅទៅស្រុកយួន។ ទៅដល់បាញ់ញ៉ៅ ត្រូវចៅហ្វាយខែត្រយួន ឃាត់ឲប្រថាប់នៅទីនោះសិន។ ស្ដេចយួន យាឡុង ទ្រង់ជ្រាបហើយ ទ្រង់ឲមន្ត្រីយួន ក្រាបទូលព្រះអង្គចន្ទថា យួននឹងជួយទំនុកបម្រុងព្រះអង្គ មិនឲដាច់ផ្លូវព្រះរាជមេត្រីទេ។ ស្ដីពីព្រះអង្គដួង ពេលយាងមកដល់ក្រុងឧដុង្គ បានជួបនឹងព្រះអង្គស្ងួន គង់រួចស្រេចនៅទីនោះ ជាមួយទ័ពសៀម រួចស្ដេចទាំងពីរព្រះអង្គ ក៏នាំគ្នាយាង ទៅស្រុកសៀម ដើម្បីយកដំណឹងទៅក្រាបទូលព្រះ

[4] ព្រះអង្គចន្ទ មាន អនុជ បីព្រះអង្គ : ព្រះអង្គស្ងួន, ព្រះស្រីជ័យជេដ្ឋ (អង្គអិម) និង ព្រះអង្គដួង។

ចៅសៀម។ ក្រោយបន្តិចមក ទ័ពយួន ដង្ហែព្រះអង្គចន្ទចូលមកស្រុកខ្មែរវិញ បោះជំរុំទ័ពនៅកំពង់លួង។ ពួកមន្ត្រីខ្ញុំរាជការខ្មែរ ក៏នាំគ្នាអញ្ជើញស្តេចយាង ទៅគង់ក្នុងព្រះបរមរាជវាំង នៅក្រុងឧដុង្គ។ ទ័ពសៀម ក៏ដកថយ ត្រឡប់ទៅស្រុកបាត់ដំបងវិញ។ ក្រោយពីនោះ ព្រះអង្គចន្ទ ទ្រង់ចាត់មន្ត្រីខ្មែរ ជារាជទូត នាំព្រះរាជសារ និង រាជបណ្ណាការ ទៅថ្វាយស្តេចសៀម ដោយផ្លូវមេត្រី។ ស្តេចសៀម ព្រះពុទ្ធឡឹតឡានភាល័យ ទ្រង់ មានព្រះទ័យអំណរពនប្រមាណ យល់ព្រមចងមេត្រីភាពជាថ្មី ជាមួយព្រះអង្គចន្ទ។ ថ្ងៃក្រោយមកទៀត ស្តេចយួនត្រាស់ប្រើមេទ័ពយួន នាំទ័ព ៣០០០ នាក់ និង ខ្មែរខែត្រត្រពាំង ១០០០ នាក់ ឡើងធ្វើបន្ទាយ នៅស្រុកមាត់ជ្រូក ហើយជីកព្រែកកាត់ចេញពីមាត់សមុទ្រ ត្រូវខែត្រពាម ចម្ងាយ ១៣២៦ ស៊ីន, ជីកពីមាត់ជ្រូក ទៅទល់នឹងទន្លេខាងកើត ចម្ងាយផ្លូវ ៣៤២ ស៊ីន ១២ ព្យាម ហើយស្រេច។ មិនយូរប៉ុន្មាន ស្តេចសៀម ត្រាស់បញ្ជាឲមេទ័ពសៀម លើកទ័ពចូលខែត្រវលាប្អៀ ជួបច្បាំងនឹងទ័ពខ្មែរ តែទ័ពខ្មែរទ្រាំពុំបាន ព្រោះទ័ពសៀម មានចំនួនច្រើនលើសទ័ពខ្មែរ។ បរាជ័យនេះនាំឲព្រះអង្គចន្ទ យាងចេញពីព្រះបរមរាជវាំង ចុះព្រះទីនាំងនាវា ទៅស្រុកយួន។ ដល់ស្រុកយួន ទ្រង់ប្រថាប់នៅស្រុកលុងហោ។ ទ័ពសៀម ចូលកាន់កាប់ក្រុងឧដុង្គ នាំមក

ជាមួយព្រះអង្គដួង[5]។ ក្រោយពីនោះមក ទ័ពសៀម នឹង ខ្មែរ ជួបច្បាំងគ្នា នៅភូមិស្មោង ខែត្រព្រៃវែង។ ទ័ពសៀម បរាជ័យ ថយទៅវិញ។ លុះរត់មកដល់ភូមិតុរិ មេទ័ពសៀម ឲសេនាទាហានរុះរើផ្ទះម្នកស្រុក ដែលរត់ចោលភូមិចងជាក្បូន រួចចំឡងកងទ័ព ទៅដាក់ខាងត្រើយ រកាកោង។ ខណៈនោះ បណ្ដារាស្ត្រខ្មែរ ប្រជុំគ្នាតាំងជាស្ម័គ្របក្សពួកទ័ពលើកទៅដេញកាប់សម្លាប់សៀម ស្លាប់អស់ជាច្រើន។ តែទ័ពសៀម ដែលលើកទៅវាយបន្ទាយយួននៅមាត់ជ្រូក ក៏មានជ័យជំនះឈ្នះទ័ពយួន។ ទ័ពសៀម ដេញទ័ពយួន រត់ដល់ពាមលុងហោ។ តែទ័ពយួន មានជ័យជំនះ វាយយកស្រុកភ្នំពេញបាន ហើយញែកទ័ពពីរផ្លូវ លើលទ័ពទៅផ្លូវទន្លេធំ និង ទន្លេសាប ទៅបង្ក្រាបខែត្រកំពង់ស្វាយ រហូតមានជ័យជំនះ លើទ័ពសៀមគ្រប់សមរភូមិ។ ទ័ពសៀមថយទ័ព ទៅស្រុកវិញអស់។ ព្រះចៅយួនថ្មី ព្រះនាម មីញម៉ាង ត្រាស់ប្រើមេទ័ពយួន ឲចាត់នាំទាហាន ឲហែព្រះអង្គចន្ទ ឡើងមកដល់ភ្នំពេញ។ ស្ដេចចតព្រះទីនាំងនាវានៅ កំពង់កោះស្លាកែត រួចទ្រង់ ត្រាស់ឲធ្វើព្រះរាជវាំងគង់នៅកោះនោះ។ ព្រះអង្គចន្ទ ទ្រង់ក៏មានអាពាធមូលជាទម្ងន់ ចូលបង្គន់ដាលោហិត។ ក្នុងព្រះជន្ម ៤៤ ឆ្នាំ ស្ដេច សោយព្រះទិពជង្គត ក្នុងព្រះទីនាំនាវា។ ព្រោះអង្គចន្ទទ្រង់គ្មានបុត្រាម្នាក់សោះ សំរាប់បន្តរាជសម្បត្តិ។ ទ្រង់

[5] ព្រះអង្គស្ងួន ទ្រង់ទីវង្គតនៅស្រុកទេពបុរី ដោយជម្ងឺជាទម្ងន់។

មាន បុត្រី ៤ ព្រះអង្គ : ព្រះអង្គម្ចាស់ក្សត្រី ប៉ែន, ម៉ី, ពៅ និង ស្ងួន។ ខាង សៀម ចង់លើក បុត្រីច្បង ព្រះអង្គម្ចាស់ក្សត្រី បែន ឲឡើងគ្រោងរាជ្យ បន្តព្រះបិតា តែ ព្រះអង្គ ប្រកែកមិនទទួល។ ចំណែក ខាងយួន មានទ័ព ឈរនៅក្រុងឧដុង្គ ពេលនោះ សេនាបតីមន្ត្រីខ្មែរទាំងឡាយ និង អុងខាំម៉ាង ជាមេទ័ពយួនប្រចាំនៅស្រុកខ្មែរព្រមអញ្ជើញ ព្រះអង្គម្ចាស់ក្សត្រីម៉ី ឲស្តេច ឡើងសោយរាជសម្បត្តិ ត ពីបិតានៅក្រុងកម្ពុជា[6]។

បន្ទាប់មក ដើម្បីទប់ទល់ឥទ្ធិពលយួន នៅស្រុកខ្មែរ ព្រះថៅសៀម ទ្រង់អនុញ្ញាតឲ ព្រះអង្គអិម (មហាឧបរាជ) និង ព្រះអង្គដួង (ឧបរាជ) វិលចូលស្រុកខ្មែរវិញ។ ព្រះស្រីជ័យជេដ្ឋ ឬ ព្រះអង្គអិម មកគង់នៅស្រុកបាត់ដំបង រីឯ ព្រះអង្គដួង មកគង់នៅខែត្រមង្គលបុរី។ នៅឆ្នាំ ១៨៣៥ អ្នកបែន ជាព្រះម្នាង នៃព្រះអង្គដួង បានសម្ភពព្រះរាជបុត្រា មួយព្រះអង្គ។ ព្រះរាជបិតា ទ្រង់ទំយើព្រះអង្គ ហៅ

[6] ព្រះអង្គអេង ឡើងគ្រងរាជសម្បត្តិ ក្នុងព្រះជន្ម ៧ ឆ្នាំ បន្តពី ព្រះអង្គនន់ ដែលយួនចាប់ដាក់ទ្រុង នាំមកសម្រេចទោសសម្លាប់ ទម្លាក់ទឹក នៅឆ្នាំ ១៧៧៩។ តែកិច្ចការរដ្ឋ គឺ សម្តេចព្រះថៅហ្វា ម៉ូ គាំពារដោយយួន ជា អ្នកចាត់ចែងត្រួតត្រាទាំងអស់។ ប៉ុន្តែប្រទេសយួន ដោយចុះខ្សោយ ព្រោះការបះបោរ នៃពួក តៃសឺង ក៏បន្ធូរដៃវិញក្រោយបន្តិចមក ហេតុដែលបើកឲសៀមត្រឡប់មកវិញ។ ស្តេចយួន យ៉ាឡុង រត់ទៅស្រុកសៀម ដើម្បីសូមជំនួយសៀម ជួយវាយ ពួក តៃសឺង។
*(note de bas de page - suite)*

ថា ព្រះអង្គច្រឡឹង មានព្រះរាជនាមថា ព្រះមង្គម្ចាស់ រាជាវតី។ ព្រះអង្គនោះ គឺព្រះបាទសម្ដេចនរោត្តម នោះឯង។

មេទ័ពយួន ដែលរក្សាស្រុកភ្នំពេញ ឈ្មោះ អុងទ្រឿងគុន[7] មានបំណងចង់បំបាត់ស្រុកខ្មែរ។ គាត់យល់ឃើញថា ព្រះអង្គម៉ីក្សត្រី មិនអាចរក្សាស្រុកខ្មែរមាំមួនទេ។ តែឥឡូវមានស្ដេចខ្មែរ ពីរអង្គមករស់ នៅលើទឹកដីខ្មែរ នៅខែត្របាត់ដំបង ដូច្នេះត្រូវប្រើឧបាយកល បញ្ឆោតបំបែកយកមហាឧបរាជ នៅទុកនៅស្រុកយួន។ លុះពិចារណាយល់ដូច្នោះហើយ គាត់ក៏ហៅយួនបីនាក់ ជាយួនចំណងព្រះហស្ដ ពីព្រះអង្គចន្ទមក តាំងងារជាអុងផ រួចប្រើឲនាំសារទៅស្រុកបាត់ដំបង ក្រាបទូល ព្រះអង្គអិម យាងព្រះអង្គឡើងគ្រងរាជសម្បត្តិ បន្តពី ព្រះអង្គចន្ទ តម្រងរាជ្យប្រពៃណី អំពីបុរាណរៀងមក។ ព្រះអង្គម៉ី ក្សត្រី ជាព្រះភាគនេយ្យា គ្រងរាជសម្បត្តិបណ្ដើរសិន គឺថាមិនមែនជាស្ថាពរទេ ព្រោះពេលនោះ ព្រះអង្គគង់នៅស្រុកសៀមនៅឡើយ។ ព្រះអង្គអិម មហាឧបរាជ ទ្រង់ជ្រាបហើយ ជឿជាក់ថា យួននិយាយនេះ ដោយសុចរិតពិតប្រាកដ។ ដើម្បីរលាស់ចោលបញ្ហាព្រះអង្គដួង ព្រះមហាឧបរាជ ឲធ្វើព្រះសុភអក្សរ ទូលស្ដេចសៀម ជាកលឧបាយ ក្លែងពោលទោស ដាក់ព្រះអង្គដួង ជាព្រះអនុជ ថា គិតកែប្រែគំនិត

[7] អុងទ្រឿងគុន ឈ្មោះដើម អុងតាគុន ជាយួនមករស់នៅស្រុកខ្មែរយូរ ហើយ បានឡើងសក្ដិ ជា អុងទ្រឿងគុន មានន័យថា មេទ័ពធំបង្អស់។

ព្រះទ័យចូលយួន ហើយមានបំណង ទៅនៅព្រះរាជវាំង ឧដុង្គវិញ។ ស្តេចសៀមទទួលហើយ ទ្រង់ជឿតាមគ្រប់ប្រការ។ ព្រះអង្គទ្រង់ចាត់មន្ត្រីសៀម ឲអញ្ជើញព្រះអង្គដួងទៅស្រុកសៀម។ មកដល់ស្រុកសៀម ព្រះអង្គដួងត្រូវសៀមឃុំមាំមួន ក្រែងរត់ទៅស្រុកខ្មែរវិញ។ បន្ទាប់មក ព្រះមហាឧបរាជ ក៏នាំមន្ត្រីរាជការ ព្រមទាំងព្រះរាជវង្សានុវង្ស យាងចុះព្រះទីនាំងនាវា រៀងមកដល់ ខែត្រពោធិសាត់។ មកដល់ទីនោះ មេទ័ពយួនប្រចាំដំបន់ ចាប់ឃុំស្តេចខ្មែរ ហើយនាំមកដល់ភ្នំពេញ។ អុងទ្រឿងគុន ចាត់សេនាទាហានយួន ឲនាំព្រះមហាឧបរាជ ព្រមទាំងព្រះរាជវង្សានុវង្ស មន្ត្រីខ្ញុំរាជការទាំងប៉ុន្មាន ចុះទៅស្រុកព្រៃនគរទាំងយប់។ រួចនាំស្តេច ចុះទៅទុក នៅស្រុកហ្វេតៃម្តង។ ចំណែក អុងទ្រឿងគុន ថ្ងៃក្រោយមក ប្រើឧបាយកលបញ្ជោត ព្រះអង្គម៉ីក្សត្រី និង ស្តេចរាជខ្មែពីរអង្គ បញ្ជូនទៅគង់នៅស្រុកហ្វេ រៀរលែងតែ ព្រះអង្គក្សត្រីប៉ែន យួនសម្លាប់ចោល ដោយចោទថា ‹ស្តេចក្បត់យួន› ព្រោះព្រះមាតា ទៅពឹងស្រុកសៀម។ រួចគាត់ ធ្វើសេចក្តីរាយការណ៍យ៉ាងពិស្តា តាមសារ ថ្វាយ ស្តេចយួន អំពីផែនការរបស់គាត់។ ស្តេចយួន យល់ឃើញថា ឧបាយកលនេះ មានប្រសិទ្ធិភាព ទ្រង់ត្រាស់បញ្ជា ឲនាំខ្លួនទាំង មន្ត្រីធំៗខ្មែរផងដែរ មកស្រុកហ្វេ។

អុងទ្រឿងគុន ឈរនៅស្រុកភ្នំពេញ បៀតបៀនព្រះពុទ្ធសាសនា បញ្ជាឲ ទាហានយួន រុះវត្តលោកសង្ឃខ្មែរ សព្វអន្លើ និង ធ្វើបាប អាណាប្រជានុរាស្ត្រខ្មែរ ឥតត្រាប្រណី។ មេទ័ពយួននោះ បង្ខំឲមន្ត្រីខ្ញុំរាជការខ្មែរ ស្លៀពាក់ជា មន្ត្រីយួន; កិច្ចការរាជការផ្ដាក់ទៅលើមេទ័ពយួន បីនាក់ អុងទ្រឿងគុន ឬ ទ្រឿងមិញយ៉ាង, ផាំវ៉ាងតា និង ត្រឹងវ៉ាងណង ដូរឈ្មោះ ភ្នំពេញ ថា ‹ណាំយ៉ាង› និង ឈ្មោះស្រុកខ្មែរថា ‹ទឹកដី មិឡាំ›។ មេទ័ពយួនទាំងបីនោះ ឃោរឃៅណាស់ មកលើរាស្ត្រខ្មែរ ដែល នាំឲខ្មែរ កើតក្ដៅក្រហាយចិត្តក្រៃពេក។ ឃើញស្ថានភាពបែបនេះ ពួកមន្ត្រីខ្មែរ និង បណ្ដារាស្ត្រគ្រប់ខែត្រ គិតឃើញដូចគ្នា ដូចជាសន្មត ងើបបះបំបោរប្រឆាំងនឹងយួន ជាកងទ័ព លើកដេញកាប់យួនសម្លាប់យួន គ្រប់បន្ទាយគ្រប់អន្លើ រត់ខ្ចាត់ខ្ចាយអស់រលីង។ យួននាំគ្នាប្រជុំគ្នា នៅ បន្ទាយពោធិសត្វ និង ភ្នំពេញ។

## អន្តរាគមន៍សៀមនៅស្រុកខ្មែរ

បន្ទាប់មក មន្ត្រីខ្មែរ នាំគ្នា ផ្ញើសំបុត្រ ផ្ញើថ្វាយស្ដេចសៀម សូមយាងព្រះអង្គដួង មកគ្រប់គ្រងក្រុងកម្ពុជា ព្រោះព្រះនគរខ្មែរ កើតចលាចលជាខ្លាំង។ បើព្រះអង្គដួងយាងមក ស្ដេចនឹងអាចកំចាត់យួន ពីបន្ទាយពោធិសត្វ និង បន្ទាយភ្នំពេញ បានពិតប្រាកដ ព្រោះបន្ទាយយួន

គ្រប់អន្លើ ទាំងប៉ុន្មាន ពួកទូលព្រះបង្គន់ កំចាត់អស់ហើយ។ ព្រះណាំងក្លាវ (ស្តេចសៀម) នៅឆ្នាំ ១៨៤២ កាលទ្រង់ជ្រាប សេចក្តីសព្វគ្រប់ហើយ ស្តេចមាន ព្រះទ័យមេត្តាករុណា ដល់សមណជីព្រាហ្មណ៍ និង បណ្តារាស្ត្រខ្មែរពាន់ប្រមាណ ហើយទ្រង់អនុញ្ញាត បើកព្រះអង្គដួង ឲមកស្រុកខ្មែរតាមសុំ។ ស្តេចចាត់មេទ័ពសៀម ឲនាំសេនាទាហាន ១៥.០០០ នាក់ ហែព្រះអង្គដួង មកក្រុងកម្ពុជា។ មកដល់ខែត្រពោធិសាត់ ទ័ពសៀម ចោមព័ទ្ធវាយបន្ទាយយួន ហើយ ទទួលបានជ័យជំនះ។ ព្រះអង្គដួង និង មេទ័ពសៀម បើកឲយួនទទួលចុះចាញ់ ចុះទូកទៅស្រុកវិញ។ យួនមកដល់ស្រុកភ្នំពេញ ក៏នាំគ្នាទាំងអស់ បន្តថែវស្រូតទៅស្រុកយួន អស់ទៅ។ ស្តេច ជៀងទ្រី (យ៉ាឡុង) ក្រុងអណ្ណាម កាលខ្មែរបះវាយយួនជាខ្លាំង ទ្រង់ព្រះចិន្តាយល់ថា ខ្មែរនាំគ្នាបះនោះ ព្រោះហេតុតែ យើងយកស្តេចខ្មែរទាំងអស់ មកស្រុកយួន។ លុះទ្រង់ព្រះតម្រិះយល់ឃើញដូច្នោះហើយ ទ្រង់ត្រាស់ប្រើមន្ត្រីយួន ហែ ព្រះអង្គម៉ី សម្តេចព្រះមហាឧបរាជ ព្រះរាជវង្សានុវង្ស ព្រមទាំងមន្ត្រីខ្ញុំរាជការខ្មែរ ឡើងមកដល់ភ្នំពេញ ដើម្បីឲអ្នកនគរខ្មែររំងាប់ក្តៅក្រហាយ។ តែមន្ត្រីខ្មែរបះបោរ ពុំជឿដូច្នោះ ក៏នាំគ្នាបះទ័ពទ្វេឡើងទៀត។ យួនកថយទ័ព នាំ ព្រះអង្គម៉ី ព្រះមហាឧរាជ ព្រះរាជវង្សានុវង្ស និង គ្រួទាំងអស់ ចុះទៅស្រុកមាត់ជ្រូក ហើយស្តេចប្រថាប់នៅទីនោះ។ ព្រះអង្គ

អិម ព្រះជន្ម៥១ឆ្នាំ ទ្រង់ព្រះអាពាធព្រះសិរ្សរោគ ជាទម្ងន់ ស្តេចសុគតនៅស្រុកមាត់ជ្រូក នៅឆ្នាំ ១៨៤៤។

ចំណែកខាងសៀម ស្តេចសៀម បញ្ជូនកងទ័ពជើងទឹក ដឹកនាំដោយព្រះអនុជ មកបោះនៅខែត្រកំពត ជាកង បម្រុង។ រីឯ ព្រះអង្គដួង និង ទ័ពសៀម ទៅធ្វើបន្ទាយត ទល់នឹងទ័ពយួន នៅព្រែកជីក ក្នុងខែត្រត្រាំង។ មិនដឹង ជាមានហេតុអ្វី ទ័ពសៀម បោះនៅខែត្រកំពត ជួបច្បាំង អស់ពីរថ្ងៃ នឹងទ័ពយួននៅខែត្រពាម ក៏លើកទ័ព ត្រឡប់ ទៅស្រុកសៀមវិញ។ នាំឲទ័ពព្រះអង្គដួង ខ្វះរបងការពារ ហុចឱកាសឲទ័ពយួន លើកចោមវាយបន្ទាយព្រះអង្គ នៅ ពេលយប់ស្ងាត់ នាំឲទាហានសៀមស្លាប់ជាច្រើន។ ព្រះអង្គ ដួង វាយតប ដោះទ័ពចេញពីបន្ទាយ ហើយលើកទ័ពត្រ ឡប់មកដល់ក្រុងឧដុង្គ ហើយស្តេចយាងប្រថាប់ នៅព្រះ ពន្លាភូមិឃ្លាំងស្បែក។ ថ្ងៃក្រោយមក ព្រះអង្គដួង លើក ទ័ពមកឈរនៅភ្នំពេញ។ នៅទីនោះ ព្រះអង្គ សាងបន្ទាយ បី មួយនៅខាងទន្លេឯកើត គឺនៅបន្ទាយដែក មួយ ទៀតនៅពាមក្បាលខ្មែរ ក្រោយមកហៅថា ពាមជ័យ ខាងទន្លេឯលិច គឺនៅព្រែកតូច មួយទៀតនៅ ព្រែក បាក់ដៃ។ នៅឆ្នាំ ១៨៤៥ មានដំណឹងថា មានទ័ពយួន ប្រមាណ ៣ពាន់នាក់ មកបោះជំរុំសឹកនៅ ខែត្រពាមជរ។ បន្ទាប់មក ទ័ពយួនវាយ បន្ទាយពាមជ័យបែក នាំឲទ័ព

ខ្មែរ-សៀម ដកថយមកនៅឯបន្ទាយពាមទន្លេតូច។ ឯទ័ពយួន ចោមព័ទ្ធវាយបន្ទាយដែក នៅទីនោះព្រះអង្គដួង ស្តេចប្រថាប់នៅ។ ច្បាំងគ្នាបានបីថ្ងៃ ព្រះអង្គដួង និង ទ័ពសៀម ក៏ដកថយត្រឡប់មកភ្នំពេញវិញ រួចបន្តទៅក្រុងឧដុង្គ ព្រោះយល់ឃើញថា បន្ទាយភ្នំពេញ មិនមាំទាំសំរាប់ទប់ទ័ពយួនបាន។ ទ័ពយួន ចូលកាន់កាប់ ស្រុកភ្នំពេញ ហើយបោះទ័ពនៅកំពង់លួង ពាមជំនីក រៀងទៅដល់កំពង់ឆ្នាំង។ បន្ទាប់មក យួននាំ ព្រះអង្គម៉ី និង ព្រះជាវង្សានុវង្ស មកគង់នៅភ្នំពេញ។ មេទ័ពសៀម យល់ឃើញថា ទ័ពយួន មកកាត់តែជិតក្រុងឧដុង្គ ក៏ចាត់សេនាទាហាន ឲចេញច្បាំងនឹងទ័ពយួនគ្រប់ផ្លូវ។ យួនច្បាំងចាញ់ ក៏ថយទ័ព ទៅប្រមូលជួបជុំគ្នានៅកំពង់លួង។ សេនាទាហានខ្មែរចាប់បានមេទ័ពយួនម្នាក់បាន នាំមកថ្វាយព្រះអង្គដួង និង មេទ័ពសៀម។ អ្នកទាំងពីរ យល់ឃើញថា ជាឱកាស អាចដោះស្រាយបញ្ហាសង្គ្រាមបាន ក៏ធ្វើចុតហ្មាយផ្ញើជូន មេទ័ពចមយួន ព្រមទាំង បញ្ជូនខ្លួនមេទ័ព ដែលខ្មែរចាប់បាន ស្នើសុំចងមេត្រីភាព ឈប់ធ្វើសង្គ្រាម។ តែមេទ័ពចមយួន មិនព្រមទទួលសំណើរ ហើយបញ្ជូន មេទ័ពយួនដែលខ្មែរចាប់បាន ប្រគល់ឲព្រះអង្គដួងវិញ។ បន្ទាប់មកយួនលើកទ័ពមកច្បាំងច្រើនថ្ងៃ តែពុំអាចយកជ័យជំនះបាន ក៏ដកថយ ទៅកំពង់លួងវិញ។ ក្រោយមក មេទ័ពចមធំយួន សុំចរចា ឈប់ធ្វើសង្គ្រាម

ជាមួយព្រះអង្គដួង តែព្រះអង្គដួង ស្នើដាក់ លក្ខខណ្ឌ ជាមុន គឺឲយួនដោះលែង ព្រះមាតា និង ព្រះរាជវង្សានុវង្ស ព្រមទាំងមន្ត្រីខ្ញុំរាជការខ្មែរ ដែលយួនឃាត់ទុក ជាមុនសិន។ មេទ័ពចមយួន ថារឿងនេះ ត្រូវចរចា ជាបីភាគី គឺជាមួយ ព្រះអង្គដួង មេទ័ពសៀម និង មេទ័ពយួន។ នៅឆ្នាំ ១៨៤៥ មានការជួបប្រជុំ រវាង ព្រះអង្គដួង បញ្ញបឌិតេជោ (មេទ័ពសៀម) អុងខាំសាយ និង អុងថាំដាន់ (មេទ័ពធំយួនទាំងពីរ) ស្ដីពីសន្តិភាព។ មេទ័ពសៀម ដាក់លក្ខខណ្ឌ ថា ព្រះចៅខ្លួន មានរាជបំណង ឲព្រះអង្គដួង ឡើងគ្រងរាជសម្បត្តិនៅស្រុកខ្មែរ ដូច្នេះ បើមេទ័ពយួន គ្មានទំនាស់នឹងលក្ខខណ្ឌខានពុំបាននេះ វានឹងអាចដោះស្រាយបញ្ហាសង្គ្រាមបានជាស្ថាពរ។ មេទ័ពយួនឆ្លើយតបថា រឿងរាជសម្បត្តិខ្មែរ ខ្លួនពុំអាចសំរេចបាននោះឡើយ ត្រូវថ្វាយទូលព្រះចៅខ្លួន ជាអ្នកសំរេច។ តែមេទ័ពសៀម បញ្ជាក់បន្ថែមថា រឿងព្រះអង្គដួង ឡើងគ្រងរាជសម្បត្តិ គឺជាលក្ខខណ្ឌខានពុំបាន របស់ព្រះចៅខ្លួន ហើយមិនអាចលើកមកចរចាបាននោះឡើយ។ មេទ័ពយួន ស្នើ ដល់មេទ័ពសៀម ថា ខ្លួនអាចដោះលែង ព្រះអង្គមី ព្រះរាជវង្សានុវង្ស និង មន្ត្រីខ្ញុំរាជការខ្មែរ បាន ដោយប្តូនឹង មេទ័ពយួន អុងថាំណាំង និង យួនផ្វា ៤០នាក់ ដែលខ្មែរចាប់បានពីជាន់មុន។ រឿងនេះ ខ្លួនត្រូវក្រាបទូលស្តេចខ្លួន ដើម្បីសុំសេចក្តីសំរេច ឯចំណែក មេទ័ពសៀម ក៏ឆ្លើយតាម

វិញថា   រឿងនេះខ្លួនក៏ត្រូវសុំអនុញ្ញាតពីព្រះរាជាខ្លួនដែរ។ តែក្នុងរយៈពេលរង់ចាំនោះ មេទ័ពយួន សុំឲសៀមដកទ័ពចេញពី ក្រុងឧដុង្គ ទៅរង់ចាំ នៅខែត្រពោធិសាត់សិន។ មេទ័ពសៀម មិនព្រមហើយ ឆ្លើយតប ថា សុំឲទ័ពយួនរុះរើបន្ទាយយួន ឲអស់ស្មើគ្នាទើបទទួលយល់ព្រមបាន។ មេទ័ពយួន និង សៀម យល់ស្របគ្នា ក៏បង្គាប់សេនាទាហានខាងយួន ទៅរុះរើបន្ទាយសៀម ឯចំណែកខាងសៀម ទៅរុះរើបន្ទាយយួន។ ក្រោយមក មានការអនុញ្ញាត ពីស្តេចសៀម និង យួន ដើម្បីប្តូរ ព្រះមាតារស់ ព្រះអង្គម៉ី ព្រះរាជវង្សានុវង្ស ព្រមទាំងមន្ត្រីខ្មែរ ប្រគល់ឲព្រះអង្គដួង និង អុងថាំណាំង ព្រមទាំងយួបថ្វា៤០នាក់ ប្រគល់ឲមេទ័ពយួន។ បន្ទាប់មកទ័ព សៀម និង យួន ក៏ដកថយចេញពីស្រុកខ្មែរទៅស្រុកខ្លួនវិញរៀងខ្លួន។

នៅឆ្នាំ ១៨៤៧ ព្រះអង្គដួង ព្រះជន្មបាន ៥២ ឆ្នាំ ស្តេចបានឡើងព្រះរាជាភិសេក សោយរាជសម្បត្តិ តពីព្រះអង្គម៉ីក្សត្រី ជាព្រះភាគិនេយ្យា (ក្មួយស្រី)។ ព្រះចៅក្រុងហ្វេបានថ្វាយព្រះនាមព្រះអង្គ ថា ‹ការម៉ាងក្វឹកក្វឹង› ប្រែជាខ្មែរថា ‹ស្តេចជាម្ចាស់លើទឹកដីអាកាស›។

នៅក្នុងរាជ្យ ព្រះអង្គដួង សៀម និង យួន គេតាំងខ្លួនជាម៉ែឪ លើស្រុកខ្មែរ។ ខាងសៀមវិញ ស្តេចសៀម កំហែង ព្រះអង្គដួង យកខែត្រ បាត់ដំបង, សៀមរាប (អង្គរក៏ត្រូវ

បានទៅសៀមដែរ), ស៊ីសុផុន, ទន្លេពៅ, ម្លូព្រៃ កំពង់ផែ ត្រាត់ និង ខែត្រកោះកុង ជា ខែត្រសៀមតែម្តង[8]។ ទោះបីព្រះអង្គដួង មិនពេញចិត្តនឹង សេចក្តីសម្រេចតែម្នាក់ឯក របស់ស្តេចសៀម តែ ព្រះអង្គគ្មានមធ្យោបាយណាមួយ សំរាប់ប្រឆាំងនឹងសៀមបាននោះឡើយ។ ខាងយួនវិញ ស្តេចយួន គេបញ្ជា ឲចៅហ្វាយខេត្តខ្មែរ ពាក់កណ្តាលទឹកដី កម្ពុជាក្រោមខាងជើង ឈប់ឡើងមកក្រុងកម្ពុជា។ ត្រូវដឹងថា នៅសម័យនោះ ហ្លួងខ្មែរ បោះបង់ ទឹកដីកម្ពុជាក្រោមទៅហើយ ដោយគ្មាន មធ្យោបាយគ្រប់គ្រាន់សំរាប់ការពារទឹកដីនោះ។

លុះដល់ខែចែត្រ (មីនា) ឆ្នាំ១៨៤៨ ពញាបឌិនតេជោ និង ពញាពេជ្រវិជ្ជ័យ ជាឧត្តសេនីយសៀម ថ្វាយបង្គំលានាំសេនាទាហាន ត្រឡប់ទៅស្រុកវិញ ទុកព្រហ្មបរិក្សឲនៅចាំហែព្រះអង្គម្ចាស់រាជាវតី (ទ្រង់នរោត្តម) និង ព្រះអង្គភិម (ទ្រង់ស៊ីសុវត្ថ) ទៅក្រុងទេពមហានគរជាក្រោយ។ លុះដល់ខែពិសាខ (មេសា) ឆ្នាំ ១៨៤៨ ទ្រង់ចាត់ឧកញ៉ាពិភក្តិរាជាហែម ព្រះអង្គម្ចាស់រាជាវតី និងព្រះអង្គភិម ទៅស្រុកសៀម ដោយមាន ការហែហម ពីសំណាក់ព្រះព្រហ្មបរិក្សសៀមផង។ លុះស្តេចខ្មែរពីរអង្គនេះ ដែលត្រូវជា ព្រះរាជ

[8] ត្រូវដឹងថា ទឹកដីខ្មែរទាំងឡាយនោះ នៅឆ្នាំ ១៨៦៧ បារាំង គេបានធ្វើសន្ធិសញ្ញា ដោយលួចលាក់ជាមួយសៀម ប្រគល់ឲសៀម ប្តូរនឹង សៀមឈប់ទារសួយសារអាករពីខ្មែរ។ ចំណុចមួយទៀត ដែលទុកជា អត្ថប្រយោជន៍ខ្មែរ គឺ ខ្មែរអាចចាប់ត្រីក្នុងបឹងទន្លេសាបបានដូចសៀម។

បុត្រព្រះបាទអង្គដួង ចូលថ្វាយបង្គំព្រះចៅសៀម ព្រះនាមព្រះណាំងក្លាវ ព្រះអង្គត្រាស់បង្គាប់មុខក្រសួង ឲធ្វើព្រះរាជវាំង ថ្វាយនៅខាងត្បូងវត្តស្រះកេត។

## ការរៀបចំប្រទេស

### វិធី នៃពិធីការនៅក្នុងព្រះបរមរាជវាំង

ថ្ងៃ១១កើត ខែអាសាឍ (សីហា) ឆ្នាំ ១៨៤៧ ព្រះបាទអង្គដួង ទ្រង់តាំងព្រះមាតារស់ជា សម្ដេចព្រះវររាជិនីខត្តិយាវង្សសិរីសង្វារ រោត្តម បរមវរា គុល្យសកល មង្គលបរមបពិត្រ។ ទ្រង់ព្រះរាជបញ្ញត្តបើប្រុស ឲឆ្លើយនឹង ព្រះមាតាព្រះអង្គថា ទទួលព្រះករុណាពិសេស បើស្រីឲឆ្លើយថា ទទួលព្រះរាជសវនីយ៍អម្ចាស់។

បើធ្វើព្រះបន្ទូលទៅណាៗឲថា ព្រះសវនីយ៍ធិបតី ភវនាថប្រកាសសុទ្ធិពិធ្យាស្រ័យ នៃ សម្ដចព្រះរាជិនី ហើយ ទ្រង់ថ្វាយព្រះសង្ហារពីរអង្គ គឺមួយអង្គរូបកិន្ទរី មួយអង្គទៀតរូបទេពធីតា នៅក្នុងប្រាសាទ។

ចំណែកមន្ត្រីខ្ញុំរាជការ និង ចៅហ្វាយស្រុក សម្រាប់ខាងសម្ដេច ព្រះទាវទាំងប៉ុន្មាននោះ ស្ដេចថ្វាយ សម្ដចព្រះវររាជិនិទាំងអស់។

ក្រោពីនោះ ទ្រង់ព្រះមេត្តាប្រោសតាំងនាម ព្រះរាជបុត្រីច្បង គឺព្រះអង្គម្ចាស់ត្រមុល ព្រះរៀមជា សម្ដេចព្រះរាជធិ

តាព្រះមហាក្សត្រី ទ្រង់តាំងព្រះអង្គម្ចាស់អ៊ូ ព្រះរាជបុត្រី បន្ទាប់ជា សម្តេចព្រះរាជធិតាព្រះស្រីវរក្សត្រី។

ទ្រង់តាំងព្រះទេពពីរ គឺទី១. អ្នកម្នាងឃ្លិចជា ព្រះមង្គលទេវី ទី២. ជាព្រះទេពីមង្គល តែគ្មានរូបទេ។

ទ្រង់តាំង ព្រះបរិយា៤នាក់គឺ ទី១. អ្នកម៉ែនាងប៉ែនជា ព្រះបរមជាតិក្សត្រី។ ទី២. អ្នកម៉ែនាងណុបជា ព្រះបរមស្រីកញ្ញា។ ទី៣. អ្នកម៉ែនាងពៅជា បងព្រះបរមជាតិក្សត្រីជា ព្រះបរមទេវធីតា។ ទី៤. អ្នកម៉ែនាងពៅជា ព្រះបរមអច្ឆរិយាអប្សរ។

ឯព្រះទេពីនិងព្រះបិយោទាំង៤នេះ បើមានការចេញទៅណាៗនោះ ទ្រង់ប្រោសព្រះរាជទានវរ ដែលមាន សន្ទិយា ឲជិះបាំងរនាំងជុំវិញ បាំងក្លោះពណ៌ក្រហម រំភាយមួយជាន់ បើប្រុស ទ្រង់ព្រខ័ណ្ឌឲឆ្លើយថា ព្រះបាទម្ចាស់ បើស្រីឲឆ្លើយថា ម៉ែ។

ទ្រង់តាំងព្រះម៉ែឃួរ៤នាក់ : ទី១. ព្រះសុជាតិនារី, ទី២. ព្រះស្រីកញ្ញា, ទី៣. ព្រះទេពលក្ខណា, ទី៤. ព្រះតរិយាអប្សរ។

ទ្រង់តាំងព្រះមេនាង៤នាក់គឺ ទី១. ព្រះម៉ែនាងស្រីបុប្ផា, ទី២. ព្រះម៉ែនាងមាលាបវរ, ទី៣. ព្រះម៉ែនាងបុស្បាកេសរ, ទី៤.ព្រះម៉ែនាងសុគន្ធបទុម។

ទ្រង់តាំង ព្រះស្នំឯកឆ្វេង៤នាក់គឺ : ទី១. អ្នកព្រះនាងផលទិពសុវណ្ណ៍, ទី២. អ្នកព្រះនាងសុគន្ធរស, ទី៣. អ្នកព្រះនាងពិដោរសយ្យភាស, ទី៤. អ្នកព្រះនាងសិរិយសសេយ្យា។

ទ្ររង់តាំងព្រះស្រីង្គា៤នាក់គឺ : ១. អ្នកនាងជាតិកិន្នរី, ២. អ្នកនាងស្រីកិន្នរា, ៣. អ្នកនាងកិន្នរីសោភា, ៤. អ្នកនាងកិន្នរាកែឡាស។

ទ្រង់តាំងក្រមការ៤នាក់គឺ : ១. អ្នកឆវីសោភ័ណ, ២. អ្នកសុវ័ណ្ណសោភា, ៣. អ្នកសោភមង្សា, ៤. អ្នកកល្យាកេសី។

បន្ទាប់មកទៀតទ្រង់មេត្តាប្រោសឲហៅចេញឈ្មោះផ្ទាល់ថា អ្នកនាងនោះៗ។

ទ្រង់តាំងព្រះអគរ័ម្នាក់មាននាមថា ព្រះអគរ័ថមក្សត្រី។

ទ្រង់តាំងអ្នកអគរ័៤នាក់គឺ : រាជានុពង រាជវង្សឧត្តឡាឯកអក្គកញ្ញា សុជាតាជាតិ។

ទ្រង់តាំងអ្នកយាយ៨នាក់គឺ : ស្រីវិសាល, ឱភាសសួនសក្តិ, នារីអន័គ្ស,វរលក្ខណ៌ះនេក, ទេពកមល, សកលភិសេក, បវរតិរេក,អគ្គឯកក្សត្រី។

ទ្រង់តាំងចាស់៤នាក់គឺ : រាជអស្ចារ្យ, រាជបរិវារក្សត្រារាជបរិស័ទ្យ,បាទចារី។

ទ្រង់តាំងទុំ៤នាក់គឺ : ទទួលផ្លង់, ប្រុងប្រក្រតី, ផលគាប់ភក្តី,ខ្ចីបម្រើ។

សេនាបតីមន្ត្រីធំតូច បើមានកាលចូលគាត់ ក្នុងពិធីបុណ្យធំ ទ្រង់ព្រះរាជបញ្ញាត្តឲស្លៀកសំពត់មានបូរជរ ពាក់អាវផាយពណ៌ ជាំងឆ័ត្រពាសព្រៃពណ៌ តាមបណ្ដាសក្ដិយួរថង់រងឡើងគាល់ ដូចរាជ្យព្រះអង្គអេងជា ព្រះវរៈរាជបិតា។

ចំណែកប្រពន្ធនាម៉ឺនសព្វមុខមន្ត្រី តាំងពី សម្ដេចចៅហ្វាទឡ្ហៈ រៀងចុះដល់សក្ដិ៧ហូពាន់ ទ្រង់ព្រះរាជទាន ឲមាននាមជា ជំទាវ តាមសក្ដិធំតូចរបស់ប្ដី។ បើមានកាលចូលគាល់ ត្រូវស្លៀកយៀនគារបបូរជរ ដណ្ដប់ស្បៃពណ៌តាមសក្ដិ។

សេនាបតីមន្ត្រី ឯក ទោ និង ឧកញ៉ាមហាទេព ឲពាក់អាវផាយ ព្រៃពណ៌ក្រហម ជាំងឆ័ត្រពាស់ព្រៃក្រហម រំភាយពីរជាន់។ មន្ត្រីសក្ដិ ៧, ៦ ហូពាន់ ឲពាក់អាវផាយ ព្រៃពណ៌ខៀវ។

## យសសក្ដិ សេនាបតី មន្ត្រីរាជការ

ព្រះអង្គ ទ្រង់មានព្រះយោបល់ថា ខ្ញុំរាជការ ដែលហត់នឿយទាំងប៉ុន្មាន ដែលមិនទាន់បាន ព្រះរាជទានបំណាច់ (គុណស្នាដៃ ដែលបានធ្វើ ប្រសើរលើសអ្នក

ទាំងពួង) ឲពេញខ្នាតជូនល្មម នឹងការហត់នឿយនៅឡើយ ស្តេចនឹងរៀបចំជា ៣ស្ថាន គឺ ស្ថានទី១ ទ្រង់តាំងទ្រង់តាំងសេនាបតី និង មន្ត្រី ឲមាន ខែត្រឡើង ដាលំដាប់។ ស្ថានទី២ គឺ តាំងមន្ត្រី ចៅហ្វាយខេត្តក្រៅ ឲមានសក្តិមានយសជាថ្មី។ ស្ថានទី៣ គឺ ប្រោសព្រះរាជទាន បំណាច់រង្វាន់ ជាវត្ថុ មាន វិញ្ញាណ និង ឥតវិញ្ញាណ តាមលំដាប់តិចច្រើន ហើយទ្រង់មេត្តាប្រោស តាំងសេនាបតី ឯកទោ ត្រី ចត្វា ជាមុន។

ថ្ងៃក្រោយ ទ្រង់តាំងមន្ត្រីរក្សាព្រះអង្គ គឺ សម្រាប់ឯកខាងស្តាំ សក្តិ ៨ ហូពាន់ ៤នាក់, ៧ ហូពាន់ ៤នាក់, ៦ ហូពាន់ ៥នាក់ សម្រាប់ឯកខាងឆ្វេង សក្តិ ៧ ហូពាន់ ៤នាក់, ៦ ហូពាន់ ៤នាក់, ៦ ហូពាន់ ៤នាក់ គឺ ឧកញ៉ាពិភក្តិឥស្សរាចាងហ្វាង សក្តិ ៩ ហូពាន់ ស្តាំ, ឧកញ៉ារក្សាឥស្សរោ ចាហ្វាង សក្តិ ៩ ហូពាន់ ឆ្វេង, ឧកញ៉ាមន្ត្រីសមសក្តិ សក្តិ ៨ ហូពាន់ ស្តាំ, ឧកញ៉ាពិភក្តិសួមសក្តិ សក្តិ ៨ ហូពាន់ ស្តាំ, ឧកញ៉ាមន្ត្រីពិភក្តិសួនសក្តិ សក្តិ ៨ ហូពាន់ ឆ្វេង, ឧកញ៉ាមន្ត្រីពិជ័យរឿណរិទ្ធិ សក្តិ ៦ ហូពាន់ ស្តាំ, ឧកញ៉ាមហាមន្ត្រីរាជឫទ្ធិ សក្តិ ៨ ហូពាន់ស្តាំ, ឧកញ៉ាមន្ត្រីឫទ្ធិជ័យ ជាញ សក្តិ ៧ ហូពាន់ ស្តាំ, ឧកញ៉ាពិជ័យរឿណរង្គ សក្តិ ៦ ហូពាន់ ស្តាំ, ឧកញ៉ាមន្ត្រីរាជរិទ្ធី សក្តិ ៨ ហូពាន់ ស្តាំ, ឧកញ៉ាមន្ត្រីរិទ្ធីជ័យ ជាញ សក្តិ ៧ ហូពាន់ ស្តាំ, ឧកញ៉ាមន្ត្រីជ័យណរង្គ សក្តិ ៦ ហូ

ពាន់ ស្តាំ, ឧកញ៉ាមន្រ្តីសិហនាទ សក្តិ ៨ ហូពាន់ ស្តាំ, ឧកញ៉ាមន្រ្តីជយារិទ្ធីរុជ សក្តិ ៧ ហូពាន់ ស្តាំ, ឧកញ៉ាមន្រ្តីរឿណរិទ្ធី សក្តិ ៧ ហូពាន់ ស្តាំ, ឧកញ៉ាមន្រ្តីចេស្តា សក្តិ ៨ ហូពាន់ ស្តាំ, ឧកញ៉ាមន្រ្តី សេនារិទ្ធី សក្តិ ៦ ហូពាន់ ស្តាំ, ឧកញ៉ាមន្រ្តីសេនារឿងរិទ្ធី សក្តិ ៧ ហូពាន់ ស្តាំ។

នាយកាន់ទង់ជ័យដើរមុខ សក្តិ ៧ ហូពាន់ ស្តាំ គឺ ឧកញ៉ាមន្រ្តីមនោតេជះ, ឧកញ៉ាមន្រ្តីសេនានារិទ្ធីសរ សក្តិ ៦ ហូពាន់ ស្តាំ, ឧកញ៉ាពិភក្តិសួនសិទ្ធ សក្តិ ៨ ហូពាន់ ឆ្វេង, ឧកញ៉ាមានៈក្រៃអារុជ សក្តិ ៧ ហូពាន់ ឆ្វេង, ឧកញ៉ាវិជិតតរង្គ សក្តិ ៦ ហូពាន់ ឆ្វេង, ឧកញ៉ាឥទ្ធិរិទ្ធចេស្តា សក្តិ ៨ ហូពាន់ ឆ្វេង, ឧកញ៉ាជំនាញជ័យយុជ សក្តិ ៧ ហូពាន់ ឆ្វេង, ឧកញ៉ាឱដុង្គចេស្តា សក្តិ ៦ ហូពាន់ ឆ្វេង, ឧកញ៉ាអាមាត្រយោធា សក្តិ ៨ ហូពាន់ ឆ្វេង, ឧកញ៉ាជ័យយុជសុន្ទរ សក្តិ ៧ ហូពាន់ ឆ្វេង, ឧកញ៉ាវិជិតសង្រ្គាម សក្តិ ៨ ហូពាន់ ឆ្វេង , ឧកញ៉ាសក្តារិទ្ធីក្រៃ សក្តិ ៨ ហូពាន់ ឆ្វេង, ឧកញ៉ា, ឧកញ៉ាសេនីនិករ សក្តិ ៦ ហូពាន់ឆ្វេង។ នាយកាន់ទង់ជ័យដើរមុខ ឧកញ៉ាមានសិទ្ធីវៃ សក្តិ ៧ ហូពាន់ ឆ្វេង, ឧកញ៉ាវិទ្ធីជរសេនី សក្តិ ៦ ហូពាន់ ឆ្វេង។

ទ្រង់តាំងមន្រ្តីរក្សាអង្គ សម្រាប់ឧបយោរាជ សក្តិ ៨ ហូពាន់ ៤នាក់, ៧ ហូពាន់ ៤នាក់, ៦ ហូពាន់ ៤នាក់ គឺ ឧកញ៉ា ពិភក្តិចក្រពត្រ សក្តិ ៩ ហូពាន់ ទោ ជាចាងហ្វាង,

ឧកញ៉ាមន្ត្រីចតុរង្គ សក្តិ ៨ ហូពាន់ ស្តាំ, ឧកញ៉ាមន្ត្រីនរេន្ទ្រ ឫទ្ធា សក្តិ ៦ ហូពាន់ ឆ្វេង, ឧញ៉ាមន្ត្រីឫទ្ធា សក្តិ ៨ ហូពាន់ ស្តាំ, ឧញ៉ាមន្ត្រីនរិន្ទ្រសេនី សក្តិ ៦ ហូពាន់ ឆ្វេង, ឧកញ៉ា មន្ត្រីវិជិតយោធា សក្តិ ៧ ហូពាន់ ស្តាំ, ឧកញ៉ាមន្ត្រីសេនា ជ័យយុធ សក្តិ ៧ ហូពាន់ ស្តាំ, ឧកញ៉ារឿណរង្គសេនា សក្តិ ៨ ហូពាន់ ឆ្វេង, ឧកញ៉ាមហាសង្គ្រាមយុទ្ធ សក្តិ ៧ ហូពាន់ ឆ្វេង, ឧកញ៉ាជយារុជ សក្តិ ៧ ហូពាន់ ឆ្វេង, ឧកញ៉ាឫទ្ធិរ ណសេនី សក្តិ ៧ ហូពាន់ ឆ្វេង, ឧកញ៉ានារាឫទ្ធិ សក្តិ ៦ ហូ ពាន់ ឆ្វេង, ឧកញ៉ាឫទ្ធីនុរក្ស សក្តិ ៦ ហូពាន់ ឆ្វេង។

ទ្រង់តាំងមន្ត្រីរក្សាអង្គ សម្រាប់មហាឧបរាជ សក្តិ ៧ ហូ ពាន់ ៩នាក់ គឺ ឧកញ៉ារក្សាភូមិន្ទរ សក្តិ ៩ ហូពាន់ ត្រី ជា ចាងហ្វាង១, ឧកញ៉ានរិន្ទ្រឫទ្ធី សក្តិ ៧ ហូពាន់ ស្តាំ១, ឧកញ៉ាសិទ្ធិវិទ្ធីក្រៃ សក្តិ ៧ ហូពាន់ ឆ្វេង១, ឧកញ៉ាមហាវិ ជ័យ សក្តិ ៧ ហូពាន់ ស្តាំ១, ឧកញ៉ាក្រៃសរវិទ្ធា សក្តិ ៧ ហូ ពាន់ ឆ្វេង១, ឧកញ៉ានារាសេនី សក្តិ ៧ ហូពាន់ ស្តាំ១, ឧកញ៉ាសេរីយោធា សក្តិ ៧ ហូពាន់ ឆ្វេង១, ឧកញ៉ាសង្គ្រាម ជយា សក្តិ ៧ ហូពាន់ ស្តាំ១, ឧកញ៉ាសេនាមានះ សក្តិ ៧ ហូ ពាន់ ឆ្វេង១។

ទ្រង់តាំងមន្ត្រីរក្សាអង្គ សម្រាប់សម្តេចព្រះវររាជិនី សក្តិ ៧ ៤នាក់ គឺ ឧកញ៉ាអភិបាលបពិត្រ សក្តិ ៨ ហូពាន់ ចត្វា ជា ចាងហ្វាង១, ឧកញ៉ាសេនាពិនិត្រ សក្តិ ៧ ហូពាន់ ស្តាំ១,

ឧកញ៉ាពិនិត្យ ពលខន្ធ សក្តិ ៧ ហូពាន់ ឆ្វេង១, ឧកញ៉ាសេនីជវ័ន សក្តិ ៧ ហូពាន់ ស្តាំ១, ឧកញ៉ាតិខន្ធសេនា សក្តិ ៧ ហូពាន់ឆ្វេង១។

មន្ត្រី រក្សាអង្គទាំងនោះ ទ្រង់ចាត់ សម្រាប់ទុកឲ ធ្វើតុលាការ ទទួលវិនិច្ឆ័យសេចក្តី ដែលបណ្តារាស្ត្រវាយស្គរថ្វាយដីកា មិនសុខចិត្តនឹងសាលក្រម នៃ សាលាដំបូង ជាឧទ្ធរណ៏ សេចក្តីផង។ បើស្តេចព្រះរាជដំណើរទៅទីណា មន្ត្រីទាំងនោះ ត្រូវស្លៀកខោជើងវែង មានជរសែសយ ហើយស្លៀកសំពត់ហូល បបូណ៍ពីក្រៅ ពាក់អាវពណ៏ ក្រវាត់ខ្សែក្រវាត់មុខប្រាក់មានក្បាច់ កាន់ដាវសៀតកាំបិតស្នៀតដើរហែមុខក្រោយ ជាទាហានជំនិតព្រះអង្គ។ ក្រោពីនោះ ស្តេចតាំងមន្ត្រី ចិន ចាម ជ្វា សក្តិ ៦-៧ ហូពាន់ ឲស្រដីត្រួតត្រារក្សានានាប្រទេស។

ព្រះអង្គរាជបញ្ញត្តិដល់នាម៉ឺនសព្វមុខមន្ត្រីឲឆ្លើយព្រះអង្គថា ព្រះករុណាថ្លៃវិសេស បើទទួលព្រះបន្ទូល ឲថា ទទួល ព្រះរាជតម្រាស់តម្កល់លើត្បូង បើធ្វើព្រះបន្ទូលចេញទៅណាៗក្តីឲថា ព្រះរាជតម្រាស់ ព្រះបាទសម្តច ព្រះរាជឱង្ការ ព្រះហរិរក្សរាមាឥស្សរាធិបតី។ បើទទួលព្រះបន្ទូលឲថា ទទួលព្រះបន្ទូលពិសេស បើធ្វើព្រះបន្ទូល ទៅណាៗឲថា ព្រះបន្ទូលពិសេស ស្តេចព្រះអង្គនោះៗ។

ទ្រង់តាំងនាមទីនាំគជេន្ទ្រ សម្រាប់គង់ ៤ គឺ គជេន្ទ្រពិមាន១, គជាឋានមង្គល១, គជសារថ្កើងថ្កល់១, គជាជល់ជាញជ័យ១។ ទ្រង់តាំងនាមព្រះទីនាំងគជេន្ទ្រ ចំឡងសឹក ១៩ គឺ ព្វ◌ាសារសិទ្ធិជ័យ, ព្វានិរភ័យ, ពិជ័យព្វា, គជាជ័យជាញ, ជំនាញគជសារ, គជសិង្ហក្រទា, គជសារស្ទុះស្ទះ, គជាតិមានោ, គជោមានះ, គជេន្ទ្របះ, គជសិទ្ធិសាយ, ហត្ថីទំលុះ, ហត្ថីស្ទុះទំលាយ, ហត្ថីស្ទុះកំចាយ, ហត្ថីជាយពលពារ, គជសីហ៏ស្ទួយស្ទែត, នេយ្យនេត្រគជសារ, គជសិង្ហក្លៀវក្លា, គជសារក្លាហានល្បី។ ទ្រង់តាំងនាមព្រះទីនាំងអស្សតរសម្រាប់គង ៤ គឺ កណ្ឋស្សវិទីរង្គ១, អស្សពាង្សជាញជ័យ១, អស្សតរនិរភ័យ១, អស្សវៃហានក្លា១។

## ពុទ្ធសាសនា និង វប្បធម៌

សេនាបតី មន្ត្រីខ្ញុំរាជការទាំងពួង បើតាមហែរ ស្តេចទៅណាៗ ទ្រង់មិនឲ បរបាញ់សត្វម្រឹគ បក្សី ទាំងឡាយ។ ចំណែកបណ្តារាស្ត្រ បើកើតក្តីនឹងគ្នា ចៅក្រមជំនុំកាត់សេចក្តី ពុំសុខចិត្តទេ ទ្រង់ឲធ្វើរឿងថ្វាយ ទ្រង់ព្រះរាជវិនិច្ឆ័យដោយយុត្តិធម៌។ ក្រោយពីនោះមក ទ្រង់មានព្រះរាជបញ្ញាមន្ត្រីរាជការ ឲធ្វើរោងទាន រួចឲបើកប្រាក់ព្រះរាជទ្រព្យចាយធ្វើភោជនាហារ ព្រះគេនភិក្ខុសាមណេរ និង ឲទានដល់ស្មូមយាចក។ មនុស្សកំសត់ ទូរគត៌ អនាថា ចូលមកទទួលព្រះរាជទានរាល់ថ្ងៃ។ ចំពោះរោងទាននោះ ទ្រង់ព្រះ

មេត្តាប្រោសឲដោរ ជាឧកញ៉ាសាធារណការ វេយ្យាមហាក្សត្រា សក្តិ៨ហូពាន់ឯក។

ទ្រង់ ទូន្មាន មន្ត្រី និង បណ្តារាស្ត្រ ឲធ្វើទានរក្សាសីល ៥ សីល ៨ ជាប្រទីពពន្លឺក្នុងព្រះពុទ្ធសាសនា។ ស្តេចទ្រង់រាជ្យប្រកបដោយ ទសពិធរាជធម៌ មិនឃ្លៀងឃ្លាត។ វេលាយប់ម៉ោង ៧-៨ ព្រះឧស្សាហ៍ ចេញសណ្តាប់ព្រះធម៌ទេសនា ដែលព្រះភិក្ខុសង្ឃសម្តែងថ្វាយ នៅចុងព្រះរាជរោង រាល់ពេល រាល់យប់ រួចទ្រង់ព្រះប្រាវព្ធសាកច្ឆាធម៌ ក្នុងព្រះត្រៃបិដក និង ប្រិក្សាច្បាប់ទំនៀមទំលាប់ក្បួនខ្នាត ពីរាជការផែនដី។ យប់ម៉ោង ១២ អធ្រាត្រ ទ្រង់ចម្រើនមេត្តាភាវនា ផ្សាយរាជកុសល ដល់អ្នកញមានគុណទាំឡាយ និង សត្វទ្វេបាទចតុប្បាទអង្គជាដើម។ ម៉ោង ៥ជិតភ្លឺ ទ្រង់លាងអង្គរជាមួយព្រះទេពី ព្រះស្នំ មុខក្រសួងក៏តាំងខ្ទះ ដាំបាយថ្វាយ។ ម៉ោង ៨ព្រឹក ទ្រង់ចេញដាក់បាត្រថ្វាយព្រះភិក្ខុសង្ឃរាល់ថ្ងៃ។ ទ្រង់ ចាត់មុខក្រសួងឲរៀបពិធីចម្រើនព្រះកេសា នៃព្រះរាជបុត្រាពីរព្រះអង្គ : ព្រះអង្គម្ចាស់សំអោក (ព្រះស៊ីសុវត្ថិ) និង ព្រះអង្គម្ចាស់ សំអ៊ូ (ព្រះស៊ីវត្ថា) ហើយ ឲហែ ព្រះអង្គម្ចាស់ទាំងពីរ ទៅ បព្វជ្ជា ជា សាមណេរ នៅព្រះវិហារវត្តពុទ្ធប្រាង្គ។ ក្រោយមកទៀត ទ្រង់បញ្ជា ឲ មន្ត្រី ហែ ព្រះអង្គទាំងពីរទៅគង់នៅស្រុកសៀម ជាមួយព្រះព្រះរៀម គឺព្រះរាជាវតី (ព្រះនរោត្តម)។ ព្រះអង្គដួង

ទ្រង់សព្វព្រះរាជហឫទ័យនឹងអក្សរសាស្ត្រណាស់។ ព្រះអង្គជាករិនិពន្ធដ៏ឆើត ត្លូកស្មាដែជាច្រើន សំរាប់ខ្មែរ។

## សេដ្ឋកិច្ចជាតិ

ក្នុងឆ្នាំ១៨៤៧ ទ្រង់ព្រះរាជ បញ្ជា មន្ត្រីខ្ញុំរាជការ ឲបោះប្រាក់បាត សម្រាប់ចាយជាបឋម នៅគែម ជុំវិញប្រាក់នោះ ទ្រង់ព្រះរាជបញ្ញត្ត ឲដាក់ពាក្យថា ព្រះនគរក្រុងកម្ពុជាធិបតី មានព្រះពុទ្ធសករាជ ចុលសករាជ ត្រង់ផ្ទៃកណ្តាល មានរូបប្រសាទនគរវត្ត ម្ខាងនៅលើផ្ទៃម្ខាងទៀត ទ្រង់ឲដាក់រូបហង្ស។ រូបហង្សនោះ គឺនាម ព្រះសំអាងហង្ស ជាចាងហ្វាង ដែលបានទៅ សិក្សាសូត្ររៀន នៅប្រទេសក្រៅបានចេះវិជ្ជាបោះប្រាក់នេះឯង។ តម្លៃនិងទម្ងន់ប្រាក់នោះមានដូចតទៅនេះ៖

១. ប្រាក់បាតធំ,ទម្ងន់៤បាត ១តម្លឹង,

២. ប្រាក់បាតតូច ទម្ងន់៤ជី,

៣. ប្រាក់ស្លឹក ទម្ងន់១ជី,

៤. ប្រាក់ហ្លួង ទម្ងន់៥ហ៊ុន។

ទ្រង់ឲបោះហ្លួងមាសចាយផង។

ហើយ ទ្រង់ព្រះរាជបម្រាម ហាមនាម៉ឺនសព្វមុខមន្ត្រីធំតូចទាំងពួង កុំឲសេពសុរា ចំណែកបណ្តារាស្ត្រនៅខែត្រ

ក្រៅ ទាំងប៉ុន្មាន ទ្រង់ព្រះរាជ បម្រាមហាម កុំឲបោះផ្ទះ ទស់ត្រី រាំងព្រៃកបិទជិតទេ ទ្រង់ឲធ្វើតែសងខាង ទុកផ្លូវ កណ្តាល ដើម្បីឲនោរាចេញចូលបានផង មច្ឆាជាតិ អាច ចេញចូល ដោយស្រួលផង បើរាស្ត្រណាមិនស្តាប់ ព្រះរាជ បម្រាមនេះទេទ្រង់នឹងយកទោសជាទម្ងន់។

ក្នុងព្រះនគរក៏សុខសប្បាយ ទំនិញអ្វីប្លែក ពីប្រទេសក្រៅ ក៏នាំមកលក់ដូរជាច្រើន ផលាហារធញ្ញជាតិ និង វត្ថុផ្សេ ងៗ ក៏បរិបូណ៌ណាស់ ហើយថោកផង។ ស្រូវ ៣៥០ ថាំង ថ្លៃ ជាប្រាក់ ២៥ បាត។

## ការរៀបចំផែនដី

ទ្រង់បំបែកខែត្រធំៗ ជាច្រើនខែត្រ។ ដូចយ៉ាង ខែត្រ បាទី ជា ៤ ខែត្រ គឺ ខែត្រ : បាទី, ភ្នំស្រួចជើងគោក, គង ពីសី ជើងគោក និង កណ្តាលស្ទឹង។ ខែត្រភ្នំពេញ ចែកជា ៤ខែត្រ : ភ្នំពេញ, ល្វាឯម ជើងទឹក, កៀនស្វាយ ជើងទឹក និង ខ្សាច់កណ្តាល ជើងទឹក។ ខែត្រ កំពង់ស្វាយ ចែកជា ៣ខែត្រ : កំណង់ស្វាយ, កំបង់លែង ជើងទឹក និង ព្រៃកក្តី ជើងគោក។ ខែត្រ ស្រីសឈរ ចែកជា ៣ខែត្រ : ស្រីសឈរ កណ្តាល, ស្រិសឈរឆ្វេង និង ត្រពាំង។ ខែត្រព្រៃកប្បាស ចែកជា ២ខែត្រ : ព្រៃកប្បាស ជើងគោក និង កោះធំ ជើងទឹក។

ទ្រង់ព្រះរាជបញ្ញត្ត ឲចៅហ្វាយស្រុកគ្រប់ខែត្រ ឡើងសេនាបតីមន្ត្រីក្នុងក្រុង ជាកំណាន់ខែត្រ តាមឋានានុសក្តិ ដូចតទៅ គឺ :

ខែត្រ កំពង់ស្វាយ, អាសន្ទទុក្ខ, បារាយណ៍, ជើងព្រៃ, កំពង់សៀម, ស្ទឹងត្រង់ ឡើង សម្តេចចៅហ្វាទឡ្ហៈ។ ខែត្រ បាទី, ព្រៃកប្បាស, កំពត, បន្ទាយមាស, ក្រាំងសម្រែ, ពាម ឡើង យមរាជ។ ខែត្រ ត្បូងឃ្មុំ, ក្រចេះ, ធ្លូង, កញ្ជរ, សំបុក សំបូរ, ទទឹងថ្ងៃ ឡើង ឧកញ៉ាវាំង។ ខែត្រ បាភ្នំ, ព្រៃវែង, រំដួល, ស្វាយទាប, ពាមជរ, លើកដែក, បញ្ញាញ, ឡើង ក្រឡាហោម។ រីឯខែត្រ ពោធិសាត់, បរិបូរ, រលាប្អៀរ, ក្រគរ, ខ្លុងក្រង, កំពង់សោម, ថ្ពង ឡើង ឧកញ៉ាចក្រី។ ខែត្រ សំរោងទង ឡើង ឧកញ៉ាពិភក្តិឥស្សរា។ ចំណែកឯខែត្រ លង្វែក ឡើង ឧញ៉ារក្សស្សារោ។ ខែត្រស្អាង ឡើង ឧញ៉ាមហាសេនាធិបតី។ ខែត្រ កៀនស្វាយ ឡើង ឧញ៉ាយោធាសង្គ្រាមធិបតី។ ខែត្រ ភ្នំពេញ ឡើង ឧកញ៉ាឥស្សរសក្តា។ ខែត្រទាំង ៣៩ ខាងលើនេះ សម្រាប់ ស្តេចទ្រង់រាជ្យ។

ខែត្រ កំពុងលែង ឡើង សម្តេចចៅពញា។ ខែត្រ កណ្តាលស្ទឹង ឡើង វង្សាអគ្គរាជ។ ខែត្រ ស្រីសឈរឆ្វេង ឡើង ឧកញ៉ាស្រីជម្នាធិរាជ។ ខែត្រ ស្រីសឈរកណ្តាល ឡើង ឧកញ៉ាវិបុលរាជ។ ខែត្រភ្នំស្រួច ឡើង ឧកញ៉ារាជតេជះ។ ៥ ខែត្រ សម្រាប់ ព្រះមហាឧភយោរាជ។

ខែត្រ ល្វាឯម ឡើង សម្តេចជេដ្ឋាមន្ត្រី។ ខែត្រ កោះធំ ឡើង ឧកញ៉ាឯករាជ។ ខែត្រ ពារាំង ឡើង ស្រីសុទិពវាំង។ ខែត្រ ខ្សាច់កណ្តាល ឡើង ឧកញ៉ាបទេសរាជ។ ខែត្រ គងពិសី ឡើង ឧកញ៉ានរិន្ទ្រាធិបតី។ ៥ ខែត្រនេះ សម្រាប់ព្រះមហាឧបរាជ។

ខែត្រព្រៃក្តី ឡើង ឧកញ៉ាអធិបតីសេនា។ ខែត្រ អន្លង់រាជ ឡើង ឧកញ៉ាវង្សានុរក្ស។ ខែត្រ មុខកំពូល ឡើង ឧកញ៉ាបវររាជា។ ៣ ខែត្រនេះ សម្រាប់សម្តេចព្រះវររាជិនី។ នៅសម័យនេះ ខែត្ររួនទាំងអស់ មាន ៥២ ខែត្រ។

## ហេដ្ឋារចនាសម្ព័ន្ធ

ក្រោយមក ព្រះអង្គ ទ្រង់បញ្ជាមុខក្រសួង ធ្វើទិញថ្ន-ក-ជាថ្នល់ពី ព្រះបរមរាជវាំងឧដុង្គមានជ័យ រៀងចុះទៅដល់កំពង់លួង ចម្ងាយ ១៦០ សិន (គឺ ៦ពាន់ ៤រយម៉ែត្រ) ក្នុងចម្ងាយ ៥០ សិន មានចារិកបោះគោលថ្ម១ ធ្វើសាលាកឹងប្រក់ក្បឿង តាមថ្នល់ ៣ អន្លើ ជិកស្រះរៀបថ្ម បូកបាយអគ្រប់ដំណាក់ មានទឹកពុំដែលដាច់ សំរាប់ភិក្ខុសាមណេរ និង មហាជននិម្មដើរទៅមក ចូលជ្រកសំណាក់ អាស្រ័យជាម្លប់ ស្រង់ឆាន់ ងូតផឹកជានិព័ន្ធកុសល រួចទ្រង់ធ្វើទិញថ្នជួលបណ្តាលរាស្ត្រ លើកដីធ្វើថ្នល់ រៀបថ្មឃាំងដី រៀងពីផ្សាភ្នំពេញ ទៅដល់ពោធិចិនតុង ក្នុងខែត្រភ្នំពេញ។ ទ្រង់ព្រះ

រាជបញ្ញា ឲកែណ្ឌរាស្ត្រ ធ្វើផ្លូវពីក្រុងឧដុង្គមានជ័យ រៀង ទៅដល់ខែត្រកំពត ទុកជាផ្លូវសម្រាប់រាជការហ្លួង។

## ការពារជាតិ

ក្រោយមក ស្តេចទ្រង់រាជ្យ ទ្រង់បញ្ជាសេនាបតីមន្ត្រីខ្ញុំរាជការ ឲកេណ្ឌបណ្ដារាស្ត្រ ធ្វើបន្ទាយឆាក ពីបឹងសំរិទ្ធិ រៀងទៅដល់ ព្រះចេតិយថ្មី តាមមាត់ស្ទឹង រៀងទៅដល់វត្តបព្វជិត ប្រយត្ន័ការរក្សាព្រះនគរ។

## ការទំនាក់ទំនង ជាមួយបរទេស

ក្រោយមក ស្តេចទ្រង់រាជ្យ ឲមហានាម៉ឺនខ្មែរ ឲអញ្ជើញព្រះរាជសារ និង បណ្ណាការ ក្រាបបង្គំទូលព្រះណាំងក្លាវ (ស្តេចទ្រង់រាជ្យសៀម)។ ក្រោយពីព្រះណាំងក្លាវ ទ្រង់សោយព្រះទិពជង្គត ព្រះអនុជជាសង្ឃ លាចាកសិក្ខាបទ ឡើងសោយរាជសម្បត្តិ បន្ត ទ្រង់ព្រះនាម ព្រះបាទសម្តេច ព្រះចមក្លាវ។ ស្តេចទ្រង់រាជ អង្គដួង តែងព្រះសុភអក្សរ ទូលទៅព្រះចៅចមក្លាវ សេចក្ដីថា : សុំឲទ្រង់តាំង ព្រះអង្គម្ចាស់ នរោត្តម ព្រះជន្ម ២៣ ឆ្នាំ ជា សម្តេចមហាឧបរាជ, ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ព្រះជន្ម ១៨ ឆ្នាំតាំងជា សម្តេចព្រះកែវហ្វា រួចសុំឲត្រឡប់មកក្រុងកម្ពុជាវិញ និងបានធ្វើរាជការ ជួតរក្សាត្រួតត្រាព្រះនគរ។ ព្រះចមក្លាវ យល់ព្រមតានសំណើរ ព្រះចៅខ្មែរ តែ អនុញ្ញាត ឲតែ ព្រះនរោត្តមតែមួយអង្គ វិលត្រឡប់មកស្រុកខ្មែរវិញ។ ក្រោយមកទើប

ព្រះអង្គ អនុញ្ញាត ឲអង្គស៊ីសុវត្ថ យាងត្រឡប់មកក្រុងកម្ពុជាវិញ។

នៅឆ្នាំ ១៨៥៧ ស្តេចទ្រង់រាជ ត្រាស់ប្រាប់ពួនឹងសេនាបតី រដ្ឋមន្រ្តីទាំងឡាយថា រាជទូតក្រុងអណ្ណាម ដែលមកឈរ នៅស្រុកព្រៃនគរ សម្រាប់រក្សា ស្ថានព្រះរាជមេត្រីនោះ ចេះតែមានគំនិតអាក្រក់ ប្រែកែជាបច្ចាមិត្រ ដោយយក ស្រុកព្រៃនគរមិនឲឡើងក្រុងកម្ពុជា។ វេលានេះ គួរយើង ពឹង ម៉ុងស៊ីញ៉រ មីស មេគណកា សាសនាកាតូលិក ជាជនជាតិ ព័រទុយហ្គេស៍ មកប្រាស័យក្នុងក្រុងកម្ពុជាជាយូរឆ្នាំ ហើយ ឲនាំព្រះរាជសារ ទៅសុំទ័ព ក្រុងបារាំងសែស មកវាយ ស្រុកព្រៃនគរ យកមកវិញ។ សេនាបតី រដ្ឋមន្ត្រីទាំង នោះ ក៏យល់ព្រមតាមព្រះរាជតម្រិះ។ ថ្ងៃក្រោយមក ទ្រង់ ប្រជុំជាមួយម៉ុងស៊ីញ៉រ មីស សុំគាត់ឲនាំសារ ទៅសុំទ័ព បារាំង មកវាយក្រុងព្រៃនគរ, បើវាយបានសម្រេចថ្ងៃណា រាជការក្រុងកម្ពុជា នឹងចេញតម្លៃប្រាក់ ៥០០ សែន ថ្វាយ រាជាការស្រុកបារាំង[9]។ ឯផ្លូវស្ពានព្រះរាជមេត្រី នៃក្រុង កម្ពុជា និងក្រុងបារិស នឹងមានសច្ចះសញ្ញាតទៅទៀត[10]។

---

[9] នាម៉ឺនសៀម ដែលមានភារៈឃ្លាំមើលស្តេចខ្មែរ ដឹងរឿងអស់ ហើយបញ្ញាញក់ហឹងរបស់ខ្លួន ដោយវាយក្បាលព្រះអង្គដួងនឹងស្បែកជើង។ ព្រះអង្គបាក់មុខខ្លាំងណាស់ តែទ្រង់ពុំហ៊ានធ្វើអ្វីតបទេ។

[10] ត្រូវដឹងថា បារាំង បានចុះសន្ធិសញ្ញាសម្ពន្ធភាពទី១ ជាមួយអណ្ណាម នៅវែរសៃ ក្នុងថ្ងៃទី២៨ វិច្ឆិកា ឆ្នាំ ១៧៨៧ ជួយជាជំនួយសឹកដល់ ស្តេចបន្ទូររាជ្យនាម ង្វៀងអាន់ ដែលកំពុងច្បាំងនឹងកទ័ពបះបោរ របស់បងប្អូនបីនាក់ ‹តៃសឺង›។ អណ្ណាម ត្រូវឲកោះត្រឡាច (ពូឡូកុងឌរ) និង កំពង់ផែទួរ៉ាន ទៅ

*(note de bas de page - suite)*

ឯខែត្រ ទ្រាំងត្រើយត្បូង, ខែត្រ បាសាក់ ព្រះត្រពាំង ក្រមួនស មាត់ជ្រូក ម្ខាងទល់នឹងមាត់សមុទ្រ ម្ខាងទល់នឹងស្រុក ព្រៃនគរនោះ រាជាការកម្ពុជា នឹងចាត់កងទ័ពទៅវាយព័ទ្ធ រៀងទៅទល់នឹងដែនក្រុងព្រៃនគរ។ ម៉ុងស៊ី

---

បារាំង។ តែ នៅពេលដែល មេគណកាតូលិក ជាទូត របស់ង្វៀងអាន់ និងជាអ្នកចរចាជាបារាំងផ្ទាល់ មកដល់កម្ពុជាក្រោមវិញ ង្វៀងអាន់ វាយយកបាន ព្រៃនគរ រួចទៅហើយ ព្រមទាំងដែនដីទិសខាងត្បូងទាំងអស់។ នៅឆ្នាំ ១៨០២ ង្វៀងអាន់ វាយឈ្នះ ពួក ‹តៃសឺង› ក្រោយបង្អស់នៅហាណូយ ហើយប្រកាសខ្លួនជា អធិរាជក្រោម ឈ្មោះ យ៉ាឡុង។ ស្តេចយួននេះ គាំពារអ្នកផ្សាយសាសនាកាតូលិក តែក្រោយមកនៅក្នុងរជ្ជកាល ស្តេច មិញម៉ាង បន្ទាប់មក ស្តេច ទីឌឹក ចាប់មានប្រទុស្តរាយនឹងបារាំង ដូចយ៉ាងការព្យាបាទធ្វើទុក្ខបុកម្នេញ លើ ពួកអ្នកផ្សាយសាសនា។ យកលេសថាដាក់ទណ្ឌកម្មលើអធិរាជយួន ទីឌឹក អំពីការសម្លាប់រង្គាល អ្នកផ្សាយសាសនាគ្រីស្ត, ណាប៉ូឡេអុង ទី៣ បញ្ជាឲលើកទ័ពបារាំងមួយកងមកវាយយួន។ ថ្ងៃទី ៣១ សីហា ឆ្នាំ ១៨៥៨, សំពៅមួយកង ដែលដឹកនាំបេសកៈយោធពល បារាំង-អេស្ប៉ាញ៉ុល ៣.០០០ នាក់ ក្រោមបញ្ជា នៃ ឧត្តមនាវី រីហ្គោ ដឺហ្សឺនូយី បោះយុតថ្កា នៅឆកសមុទ្រ ទូរ៉ាន់។ ជាបឋម បារាំងស្នើសុំយួនប្តូរ កុងស៊ុកជាមួយគ្នា ប៉ន្តែ ចំពោះមុចចំនួនស្លួចស្តើង នៃទ័ពបារាំង អធិរាជយួន ទីឌឹក ទាត់ចោលសំណើនេះ។ ដូច្នេះ ពី ទូរ៉ាន់ មេទ័ពបារាំង គិតគូរវាយរាជធានី ហ្វេ។ ប៉ុន្តែ សំពៅបាញ់កាំភ្លើងធំ របស់ខ្លួន ពុំអាចចូលតាមស្ទឹងហ្វេបានឡើយ។ ក្រោយពីកងសំពៅ បាននឹងថ្កល់យ៉ាងយូរ, ដឹហ្សឺនូយី សំរេចប្តូរទីដៅ: ឬមួយ វាយតុងកឹង ឬមួយ វាយកម្ពុជាក្រោម។ ដោយយល់ថា ខ្យល់រដូវរងា នាំសំពៅមកកម្ពុជាឆាប់ជាង, កងទ័ពបារាំងក៏ចុះមកខាងត្បូង ហើយឡើងតាមស្ទឹងព្រៃនគរ ហើយវាយយួនសំរុក នៅថ្ងៃទី ១៧ កុម្ភៈ ឆ្នាំ ១៨៥៩។ ចម្បាំង បារាំង-យួន បន្តរហូត ដល់ឆ្នាំ ១៨៦០ នៅឆ្នាំនោះ នាវាបារាំង ចំនួន ៧០ មកពីស្រុកចិន ហើយមិនត្រឹមតែវាយបំបែកបាននូវការឡោមព័ទ្ធយួនទេ ថែមទាំង កាន់កាប់ខែត្របីនៅខាងជើង ព្រៃនគរ។ ថ្ងៃទី ៥ កក្កដា ឆ្នាំ ១៨៦២ ទីឌឹក ដោយរវល់នឹងការបះបោរ នៅតុងកឹង សុខចិត្តចុះសន្ធិសញ្ញាជាមួយបារាំង (ឧត្តមនាវី បោណ្ណា) ដែលនៅក្នុងនោះ អធិរាជយួន អនុញ្ញាត សេរីភាព ឲជនជាតិយួនកាន់សាសនាកាតូលិក ហើយឲខែត្របី (បៀងហ្វា, យ៉ាឌិញ និង វិញឡុង) និងកោះត្រឡាច ទៅបារាំង។ នៅ ខែ កញ្ញា ១៨៦២ ឧត្តមនាវី មកធ្វើទស្សកិច្ចដល់ព្រះបាទនរោត្តម នៅ ឧដុង្គ។ ទស្សនកិច្ចនេះ ជាការស្ទាបស្ទង់មើលក្រែងអាចទាញកម្ពុជាក្រោម ដាក់ក្រោមការការពារបារាំងបាន។ នៅសម័យនោះ បារាំង រកផ្លូវទឹកមួយ ចូលមកប្រទេសចិនខាងត្បូង ដើម្បីធ្វើជំនួញ។ បើត្រួតត្រាកម្ពុជាបាន គឺថែមទាំងភូមិភាគ បង្កាទុកខាងមុខទៀត សំរាប់ពេលណា មានការយីយាពីស្រុកសៀម ដែលបានត្រូវពួកអង់គ្លេស គាំទ្ររួចទៅហើយ។

---

ញ៉ូរ មីស ក៏ទទួលតាម ព្រះរាជឱង្ការ គំនាប់ អញ្ជើញព្រះរាជាសារ ចេញទៅក្រុងបារីស លុះដល់ ក៏ថ្វាយ ព្រះបាទ ណាប៉ូឡេអុងទី៣។ ព្រះអង្គ ក៏ទ្រង់មេត្តាប្រោស តាមព្រះរាជសារ គ្រប់ប្រការ។

## ព្រឹត្តិការណ៍សំខាន់ៗ នៅក្នុងព្រះនគរ

កាលក្រោយដែល ម៉ុងស៊ីញ៉ូរ មីស អញ្ជើញព្រះរាជាសារ ទៅក្រុងបារីសនោះ ព្រះមហាក្សត្រ អង្គដួង ទ្រង់ចាត់ ឧកញ៉ារាជាសេដ្ឋី កែប ថៅហ្វាយស្រុកពាម ជាមេកង និង សេនាទាហាន ព្រមដោយសាស្ត្រាវុធ បម្រុងស្រេច, ចាត់ ឧកញ៉ាយមរាជ ម៉ុក ជាអ្នកចាត់ចែង បញ្ជូនស្បៀងអាហារ បម្រុងចាំកងទ័ព ពីក្រុងបារាំងសែសមកដល់ នឹងវាយផ្ទប់គ្នា។ ទ្រង់ចាត់ ព្រះអង្គនរោត្តម ឲ្យត្រួតត្រាធ្វើទូកចម្បាំងមាំមួន គួរនឹងការណ៍។ ព្រះអង្គនរោត្តម ទ្រង់គង់នៅព្រះរាជវាំងចាស់ ចំណែក ព្រះអង្គដួង ទ្រង់គង់នៅព្រះបរមរាជវាំងថ្មី ទ្រង់បញ្ញាឲហៅថា ព្រះបរមរាជវាំងស្រះសារពើយុធ ក្រុងឧដុង្គមានជ័យ។

មាន ជនផ្ទាម្នាក់ ងារជាសម្តេចបូទេស លី រួមជាមួយឧកញ៉ាបវរអនុរា ហឹម, ឧកញ៉ាសេនាច័ក្រព័ត្រ សួរ និងទួនស្និត ជាបងប្អូនបង្កើតនឹងគ្នា ក្នុងខែត្រត្បូងឃ្មុំ បំបះ

រាស្ត្រ កឡើងជាទ័ព លើកដេញ ឧកញ៉ាពិភក្តិឥស្សរា ភោគជាព្រះរាជអង្គាលួង ដែលឈរខែត្រត្បូងឃ្មុំ។ ដឹងដំណឹងនេះភ្លាម ស្តេចទ្រង់រាជ ដឹកនាំកងទ័ព ទៅបង្ក្រាប ពួកឧទ្ទាម ប្រកបដោយជោគជ័យ។ មេបះបោរទាំងឡាយ នាំគ្នារត់ទៅពឹងយួនឲជួយពួកខ្លួន។

នៅឆ្នាំ ១៨៥៨ ស្តេចទ្រង់រាជ ដឹងដំណឹងថា ឧត្តមនាវីបារាំង នាម រីហ្គោ ដឺហ្សឺនូយី នាំសេនាទាហាន មកដល់កំពង់ផែ ទូរ៉ាន់ មានទាំងនាំសារ ព្រះចៅ ណាប៉ូឡេអុង ទី ៣ យល់ព្រមជួយព្រះអង្គ តាមសេចក្តីស្នើ ទ្រង់ក៏បញ្ជាឲឧកញ៉ា កែប លើកទ័ពវាយទ័ពយួន នៅគ្រប់ខែត្រ ដែលបានគ្រងទុកជាមុន។ តែការវាយនេះ វាគ្មានប្រៀបអ្វីលើយួននោះឡើយ។ ចំណែក ព្រះអង្គដួង ទ្រង់ចេញព្រះរាជដំណើរ ជាមួយ ព្រះមាតា ព្រះរាជវង្សានុវង្ស ព្រះស្នំ ទៅប្រពាតនៅ ខែត្រកំពត។ លុះទ្រង់ប្រថាប់នីទីនោះយូរខែទ្រង់ចាប់អាពាធ ព្រះអថ្សារោគ គឺ ឫសដូងបាត។ ស្តេចក៏យ៉ាងត្រឡប់មកក្រុងឧដុង្គមានជ័យវិញ។ ក្រោយបន្តិចមក ពួកឧទ្ទាម ដែលទៅពួនលាក់ខ្លួនជាមួយយួន នាំគ្នាបំបះ ពួកចាម ជ្វា កជាកងទ័ព វាយ ស្រុក ភ្នំពេញ និងក្រុង ឧដុង្គ ផង។ ជា ដំបូង កងទ័ព ឧទ្ទាម ដឹកនាំដោយទួនស្អិត មានជោគជ័យលើសមរភូមិ គ្រប់អន្លើ។ ព្រះអង្គដួង ទ្រង់ ត្រាស់បញ្ជា ឲស្តេច នរោត្តម និង ស៊ីសុវត្ថ ពីរ

នាក់បងប្អូន ដឹកនាំទ័ព ទៅបង្ក្រាប ការបះបោរ។ ស្ដេចទាំងពីរ បញ្ជាឲរកចាប់មេធំ ពួកឧទ្ទាម ឈ្មោះ ទួនផរ។ ពេលនោះមានសំឡិច ពីបក្សពួកចាមជ្វា ទៅប្រាប់មេកង ខាងពួកចាមជ្វាថា ទួនផរ ស្ដេច ឲចាប់ធ្វើទោសទៅហើយ។ ដឹងដំណឹងនេះ ហើយថែមទាំងឃើញ ស្ដេចទាំងពីរអង្គ យាងមកដល់ ទីជុំរុំទ័ពខ្លួនថែមទៀតទៀត ពួកចាមជ្វាក៏នាំគ្នា រត់ពួនបាត់អស់ លែងហ៊ានចេញមុខច្បាំង។

នៅឆ្នាំ ១៨៦០ ព្រះបាទអង្គដួង ទ្រង់ សោយទិព្វជង្គត នៅក្នុងជន្មាយុ ៦៥ ឆ្នាំ។ សេនាបតីរដ្ឋមន្ត្រី និង ព្រះរាជវង្សានុវង្ស បានអញ្ជើញ ព្រះនរោត្ដម ជាព្រះរាជបុត្រច្បងអោយឡើយ គ្រងរាជសម្បត្តិ បន្តពីព្រះវរបិតា តាម បណ្ដាំរបស់ព្រះអង្គ។ ព្រះអង្គដួង ទ្រង់មានព្រះរាជបុត្រា ៨, ព្រះរាជបុត្រី ៩ រួមជា ១៧ ព្រះអង្គ។

ព្រះអង្គមានព្រះរាជបណ្ដាំសម្ដេចចៅហ្វាទឡ្ហៈថា បើទ្រង់សោយទិពជង្គតទៅ ឲវះពន្លះព្រះមង្សះទ្រង់ ឲទានសត្វទ្វេបាទ និង ចតុប្បាទ អដ្ឋបាទ បរិភោគជាអាហារចុះ។

# អត្ថធិប្បាយ ជា អត្តនោម័តិ[11]

## កម្លាំង និង ទុព្វលភាព របស់ព្រះអង្គដួង

ស្រុកខ្មែរ ចាប់ពី សតវត្សទី១៨ មានស្ថានភាពដុនដាប ណាស់ទៅហើយ ហើយក្លាយជា ប្រទេសចំណុះយួន។ នៅក្នុង រជ្ជកាល ព្រះអង្គចន្ទទី២ ដែលជាហ្លួងរណបយួន ស្រុកខ្មែរ ក្លាយជាចំណី នៃមហិច្ឆិតា របស់ប្រទេសយួន និង សៀម។ ប្រទេសទាំងពីរនេះ នាំបង្កើតសង្គ្រាមនៅស្រុកខ្មែរ ពន្លិច ស្រុកខ្មែរ ទៅក្នុង ទុក្ខវេទនា ហួសប្រមាណ។ ស្តេចទ្រង់រាជខ្មែរទាំងឡាយ លែងជាម្ចាស់ លើវាសនា របស់នគររបស់ខ្លួន ហើយ ដើម្បី រក្សារាជបល្ល័ង្គ ពី ការបះបោរ ដណ្តើមរាជ្យ ពីសំណាក់ ស្តេចដទៃទៀត ក្នុង ព្រះរាជវង្សានុវង្ស ត្រូវចាំបាច់ ទៅពឹងពាក់បរទេសឲ្យជួយ ដោយសន្យានឹងជូនរង្វាន់សមតាមការណ៍។ ស្រុកយួន និង សៀម ជា ស្រុកជម្រក ឬ សំណាក់ របស់ស្តេចខ្មែរ ទាំងឡាយ ភៀសខ្លួនទៅសុំស្នាក់នៅ រង់ចាំ ហ្លួង យួន និង សៀម សម្រេច ជួយខ្លួន មក ជ្រែករាជ្យ ឬ មក គ្រងរាជសម្បត្តិ ជា មហាក្សត្រចំណុះបរទេស។ ខាងសៀម ព្រះចៅសៀម ជា អ្នកជ្រើសរើស ស្តេចខ្មែរ ឲឡើងគ្រងរាជសម្បត្តិនៅក្រុងកម្ពុជា។ រាជបុត្រ មានឋានៈជា ព្រះអង្គម្ចាស់រាជ្យខ្មែរទាំងឡាយ ត្រូវទៅ រស់នៅរៀនសូត្រ ជាចាំបាច់ នៅស្រុកសៀម រហូត

[11] អត្តនោម័តិ, យោបល់ផ្ទាល់ខ្លួន, opinion personnelle។

មានការអនុញ្ញាត ពីហ្លួងសៀម ទើបអាចវិលត្រឡប់មក ស្រុកខ្មែរវិញបាន។ ហ្លួងសៀម ជាអ្នកបំពាក់ងារ ឲស្តេចខ្មែរ ដូចយ៉ាងងារ ជា ឧបយោរាជ, ឧបរាជ ជាអាទិ។ ខាងយួន ព្រះចៅអណ្តាម ត្រួតត្រាផ្ទាល់ រួចស្រេច ចៅហ្វាយខេត្តខ្មែរ មួយចំនួនធំ នៅកម្ពុជាក្រោម ហើយ ហាមឈប់ឲឡើងរាជការខ្មែរ នៅក្រុងឧដុង្គ។ ទឹកដីស្រុក ខ្មែររួញតូច ហើយ ស្រុកខ្មែរ បាត់ ជីវកម្លាំង សំរាប់ទ្រទ្រង់ ខ្លួនឯងបាន។ ប្រជាពលរដ្ឋខ្មែរ ក្លាយជា ចំនួនបុគ្គល : ជាឧបករណ៍ មួយក្រុម រស់នៅក្រោមអំណាចសៀម, មួយ ក្រុម រស់នៅក្រោមអំណាចយួន ហើយមួយចំនួនទៀត រស់ នៅក្រោម អំណាចរាជការខ្មែរ ក្រខ្សត់ណាស់។ ឯកភាព ជាតិ គឺ បែកខ្ទេច គ្មានគម្ចាស់ណាមួយ អាចនឹងលើក ចងផ្សាប់គ្នាបានវិញនោះឡើយ ព្រោះ សៀម និង យួន គេ មានល្បិចច្បាស់លាស់ ដ៏ប្រសប សំរាប់ស្រូបទាំងផ្លូវកាយ និង ចិត្ត ជនខ្មែរបានងាយស្រួលបំផុត។ នៅស្រុក សៀម និង យួន ក៏មានសង្គ្រាមស៊ីវិល ដណ្តើមអំណាចគ្នាច្រើន នោះដែរ តែទឹកដីគេកាន់តែរីកធំឡើង ចំណែកស្រុកខ្មែរ កាលណាមាន សង្គ្រាមម្តងណា ក្នុងព្រះរាជវង្សានុវង្ស គឺ ច្បាស់ជាទឹកដីខ្មែរ រួញជានិច្ច។ សួរថា មកពីហេតុអ្វី ? ព្រោះ ស្តេចខ្មែរ ទាំងឡាយ ជាគូប្រយុទ្ធ តែងតែទៅពឹង ពាក់បរទេស ដើម្បី ការពារប្រយោជន៍ខ្លួន ដាច់មុខ ទោះបីខ្លួន ត្រូវដូរនឹង ប្រយោជន៍ជាតិ ក៏ហ៊ានដូរ នោះ

ដែរ ៩តែខ្លួនបានឈ្នះ។ ក្រោយមកទៀត គឺ សៀម និង យួន តែម្តង គេជា អ្នកបង្កើត សង្គ្រាម លើទឹកដីខ្មែរ ដើម្បី ជ្រើសរើស ស្តេចចំណុះគេ ហើយទាមទារដោយបង្ខំ ជានិច្ច នូវគុណបំណាច់ របស់គេ ជា រង្វាន់ទឹកដី។ ដូច នោះ សង្គ្រាម រវាងខ្មែរនិងខ្មែរ ជា សង្គ្រាម គាំពារដោយ បរទេស និង ជួយបរទេសផង ដែលនៅក្នុងនោះគ្មាន ប្រយោជន៍ជាតិបន្តិចនោះឡើយ។ នៅពេល ខ្មែរឈ្នះចាញ់ គ្នា នាំអោយកម្លាំងជាតិ ចុះខ្សោយក្រៃលែង នៅមុខទ័ព បរទេស ដែលគេមកជួយ ដូច្នេះ ទ័ពបរទេស គេចង់បាន អ្វីពីខ្មែរ ក៏ខ្មែរ មិនហ៊ានជំទាស់នោះដែរ។ នៅពេលនោះ គំនិតជាតិនិយមខ្មែរ វាអាចនឹងមានដែរ តែវាគ្រាន់តែ ជាគំនិត មាននៅក្នុងអារម្មណ៍សុទ្ធសាធ។ រីឯ សង្គ្រាម ស៊ីវិល នៅស្រុកសៀម និង យួន, ជួនកាលគេ តម្រូវខ្មែរ អោយ បញ្ជូនទ័ពទៅជួយគេទៀត, ច្រើនមានលក្ខណៈ ជាសង្គ្រាម រកឯកភាពជាតិ ហើយនៅពេលដែលគេចាញ់ឈ្នះ គ្នា គឺប្រាកដ ជាជាតិគេ មានឯកភាព ជានិច្ច។

ព្រះបាទអង្គដួង ទ្រង់ ទទួលមរតក នូវស្ថានភាពស្រុក ទ្រុឌទ្រោមខ្លាំងណាស់មកហើយ។ តែ ព្រះអង្គ ក៏ជាអ្នករួម ចំណែកមួយភាគ នៃ វិនិបាតជាតិ នោះដែរ។ ដូចយ៉ាង ការក្បត់ព្រះអង្គចន្ទ ជាហ្លួង ជា ព្រះរៀម ទៅចូលសៀម វាគ្មាន លក្ខណៈជាប្រយោជន៍ជាតិនោះឡើយ។ នោះបើ ស្តេច

អង្គដួង លើកហេតុផលថា ទ្រង់មិនស្រមនឹងព្រះរៀម នៅចងមេត្រី ជាមួយយួន តែ ហេតុផលនេះ វាគ្មានមានចំណុចត្រង់ណាមួយ ដែលអាចចាត់ទុកថា ជាជម្រើស សំរាប់ការពារ ប្រយោជន៏ជាតិសោះឡើយ។ តើ សៀម នៅពេលនោះ មានបំណងចង់ជួយខ្មែរ ដែរឬទេ ? ចម្លើយថាគ្មានទេ។ ពេលនោះ សៀមគ្រាន់តែចង់អោយសញ្ញា ទៅយួនថា សៀម មិនអនុញ្ញាតអោយយួនបំពានលើ ផលប្រយោជន៏សៀម នៅស្រុកខ្មែរនោះឡើយ។ ដូច្នេះ ជម្រើសយកខាង សៀមក្តី ខាង យួនក្តី វាគ្រាន់តែជាជម្រើសការពារប្រយោជន៏ សៀម និង យួន តែប៉ុណ្ណោះ។ ជម្រើសព្រះអង្គចន្ទ យកយួន ជា អាណាព្យាបាល ព្រោះ ទ្រង់ខ្លាចសៀម ចំណែក ព្រះអនុជ របស់ព្រះអង្គទាំងឡាយ ជ្រើសយកសៀម ប្រឆាំងនឹងទ្រង់ ក៏ព្រោះ តែខ្លាចសៀមដែរដូច្នេះ វាជា ការបំបែកកម្លាំងជាតិ ដើម្បី ការពារប្រយោជន៏អាត្មា ព្រោះតែខ្លាចបរទេស។ ការខ្លបខ្លាច បរទេសរហូតបាក់ស្បាត នោះឯង វាជា ជម្ងឺសតិ នៃស្តេចខ្មែរទាំងឡាយ ក្រោយពីសម័យលង្វែកមក ដែលនាំឈប់ឲមានការទុកចិត្តគ្នា នៅក្នុង ព្រះរាជវង្សានុវង្ស និង រវាងស្តេច នឹងសេនាមន្ត្រី។ ហ្លួងសៀម ទ្រង់យកបុត្រាហ្លួងខ្មែរមកអប់រំ ចិត្តគំនិត ឲមានអារម្មណ៏ជាសភាវគតិខ្លាចអំណាចសៀម។ ទ្រង់ទទួល ឲជ្រោកកោនជានិច្ចដល់សេនាមន្ត្រីខ្មែរណា ដែលរត់មកសុំព្រះអង្គ ព្រោះខ្លួន មាន


សរសេរ ដោយ ឧប សៅ សង្ខា
៨ កុម្ភៈ ២០១៨

ការអាក់អន់ចិត្តនឹងស្ដេចខ្មែរ ឬ ជម្លោះ រវាងមន្ត្រីនឹងមន្ត្រី។ ស្រុកសៀម ក្លាយជា ជំរុំ នៃ ជនខ្មែរបម្រុងទាំងឡាយ ទាំងស្ដេច ទាំងរាស្ត្រ សំរាប់ស្ដេចសៀម ប្រើមកប្រឆាំងខ្មែរនៅស្រុកខ្មែរ ដើម្បីប្រយោជន៍សៀម។ នៅកម្ពុជាក្រោម យួន និង ចិន គេរួមគំនិតគ្នា បញ្ចេញចោល នូវអាជ្ញាធរខ្មែរ ហើយ គេនាំគ្នា តែងតាំង អាជ្ញាធរថ្មី សំរាប់ត្រួតត្រាផ្ទាល់ លើសហគមន៍ របស់គេ ដែលមាន ចំនួនកាន់តែច្រើនឡើងៗ រហូតលើស ចំនួនប្រជាពលរដ្ឋខ្មែរជាម្ចាស់ស្រុកទៅទៀត។ កម្ពុជាក្រោម ជាការណ៍ ក្លាយជាទឹកដីយួន តាម ចរភាព នៃ អន្តោប្រវេសន៍ នៃជនជាតិយួនកុះករ ចូលមករស់នៅ។ នៅចំពោះមុខ បាតុភូតនេះ ហ្លួងខ្មែរ ទាំងឡាយ ទ្រង់ គ្មានមធ្យោបាយអ្វីនឹងឃាត់ឃាំងរាំងរាវាបាននោះឡើយ។ ទ្រង់គ្រាន់តែបានសំដែងនូវការព្រួយបារម្ភ ដោយ ខកចិត្តតែប៉ុណ្ណោះ។

ព្រះអង្គដួង ទ្រង់ ឡើងគ្រងរាជសម្បត្តិ ដោយមានការព្រមព្រៀងគ្នា រវាង សៀម និង យួន ក្រោយពីមានសង្គ្រាម រវាងប្រទេសទាំងពីរ នៅលើទឹកដីខ្មែរ។ ការណ៍នេះជា លក្ខខណ្ឌសំខាន់ គោងតែង ព្រះអង្គដួង ត្រូវតែគោរពវា។ លក្ខខណ្ឌនោះ កំរិត រាជអំណាច និង សេរីភាព របស់ព្រះអង្គ ក្នុងការដឹកនាំ នៃ កិច្ចការរាជការខ្មែរ។ អត្ថប្រយោជន៍ របស់ព្រះអង្គមួយ គឺ ព្រះអង្គ ឥតមានគូ

ប្រដែងរាជ្យព្រះអង្គ ព្រោះព្រះរៀម ទាំងឡាយ សុគត ទាំងអស់ ហើយ ខ្សែញាតិវង្ស របស់ព្រះអង្គចន្ទ ដែលជាខ្សែពេញច្បាប់ បន្តរាជសម្បត្តិ គ្មានព្រះបុត្រាមកុដម្នាក់សោះ។ អាស្រ័យហេតុនេះដែរ ដែរ សៀម និង យួន គេយល់ព្រម អោយព្រះអង្គដួង ឡើងគ្រោងរាជសម្បត្តិ បន្តពីព្រះអង្គចន្ទ ព្រោះគេទុករជ្ជកាលព្រះអង្គក្សត្រីម៉ី គ្រាន់តែជាវង់ក្រចក ជាគ្រោះថ្នាក់មួយតែប៉ុណ្ណោះ។

ទោះបី ព្រះអង្គ ព្យាយាម រៀបចំផែនដី ជាថ្មី, ចង ជាច្បាប់ពិធីការ ច្បាស់លាស់ សំរាប់ ព្រះរាជវង្សានុវង្ស និងសេនាមន្ត្រី, ពង្រីក នូវក្បួនសីលធម៌ និង ពង្រិក នូវវប្បធម៌ជាតិ ក្នុងការរស់នៅ នៃប្រជាពលរដ្ឋ តែ សង្គមខ្មែរយើង នៅពេលនោះ ហេវកម្លាំងខ្លាំងណាស់ សំរាប់ ដើបឈរដោយខ្លួនឯងបាន ព្រោះស្រុកខ្មែរ គ្មាន គម្ពាស់សេដ្ឋកិច្ចជាតិ សំរាប់ ធ្វើអភិវឌ្ឍន ជាមាត្រដ្ឋានជាតិ។ សេដ្ឋកិច្ចរស់នៅជាប្រក្រតី មានសុវុឌ្ឍិកម្ម ព្រោះប្រទេសមានសន្តិភាព តែប្រជាពលរដ្ឋខ្មែរ រស់នៅក្នុងភាពក្រលំបាកក្រៃលែង។ អ្វីដែលធ្វើបាន ឬ រកបាន គឺ គ្រប់គ្រាប់ មិនទៀង សំរាប់តែក្រពះតែប៉ុណ្ណោះ។ ចំនួនប្រជាពលរដ្ឋខ្មែរចុះថយខ្លាំងណាស់។ នៅដើមសតវត្សទី២០ ចំនួន មានមិនដល់ ១លាន នាក់ផង។ ការបែងចែក នៃ ទីលំនៅរបស់ប្រជាពលរដ្ឋ លើផ្ទៃប្រទេស គ្មានភាពស្មើគ្នានោះឡើ

យ។ សន្ទភាពប្រជាជន ច្រើនកុះករ មាននៅដំបន់ពុំព៉ា ខាងត្បូងនៃដងទន្លេមេគុង ដែលជាដីរាបស្មើ ចំណែក ជនរស់នៅតិចតួចតួចណាស់។ ខ្មែរ មិនចូលចិត្ត រស់នៅ តាមឆ្នេរសមុទ្រ និង កោះ សោះឡើយ។ ដំបន់ទាំងនោះ ស្ទើតែគ្មានប្រជាជនខ្មែរ រស់នៅ ដែលនាំឲរាជការខ្មែរ មិនសូវរវល់ យកចិត្តទុកដាក់។ ជាឱទាហរណ៍ ចៅហ្វាយ ខែត្រកោះកុង មិនទៅរស់នៅក្នុងខែត្រ នៅក្រោម អភិបាល របស់ខ្លួន នោះទេ ទីមួយគ្មានផ្លូវទៅ និង មាន ប្រជាជន រស់នៅតិចតួចណាស់។ នៅក្នុង រាជានុសិទ្ធិ ស ម្តេច ចៅហ្វាបែន[12] ចំនួន មនុស្សប្រុសខ្មែរ មានតិចជាង

[12] សម្តេចចៅហ្វាបែន ជា មេទ័ពខ្មែរមានថ្វីដៃណាស់ នៅក្នុងរជ្ជកាលព្រះ អង្គអេង (១៧៧៩-១៧៩៦) ដែលមាន រាជានុសិទ្ធិ នាម ចៅហ្វាម៉ូ ព្រោះ ព្រះ អង្គអេង ទ្រង់នៅជាកុមា មាន ព្រះជន្ម ៧ ឆ្នាំ នៅពេលឡើងសោយរាជស ម្បត្តិ។ ចៅហ្វាបែន បានត្រូវ ចៅហ្វាម៉ូ ចាប់បញ្ជូនទៅស្រុកសៀម ដោយ ចោទថាក្បត់នឹងសៀម ហើយ ត្រូវ ស្តេចសៀម (ព្រះចៅតាក) ជេរបន្ទោស ដាក់ទោសជាទម្ងន់ គឺ វាយខ្នង ១០០ រំពាត់ និង ចៀរស្លឹកត្រចៀកទាំង សងខាង។ នៅស្រុកយួន មានការបះបោរ នៃពួកតៃសឺង ប្រឆាំងនឹងស្តេ ចយ៉ាឡុង នាំឲទ្រង់រត់ទៅស្រុកសៀម ដើម្បីសុំជំនួយ ត្រឡប់មកច្បាំងវិញ។ នៅពេលនោះដែរ ពញា ស៊ួ ជាមេទ័ពខ្មែរ មានគំនិតក្បត់នឹង ចៅហ្វា ម៉ូ លួចធ្វើសំបុត្រ ថ្វាយជូនស្តេចសៀម សុំខ្លួន យមរាជ បែន ឲត្រឡប់មក ស្រុកខ្មែរវិញ ដើម្បីនឹងបានគិតការកំចាត់ចៅហ្វា ម៉ូ។ ស្តេចសៀម (ព្រះពុទ្ធ យ៉តចូឡាលោក) ទ្រង់អនុញ្ញាត តាមសេចក្តីសុំ ថែមទាំង ព្រះរាជទានដាវ ស្រោមមាសមួយជាអាជ្ញាសឹក ដល់ យមរាជ បែន។ បែន និង ស្នងគ្របក្ស មានថ្វីដៃ ១០នាក់ វិលត្រឡប់ចូលស្រុកខ្មែរ ហើយធ្វើល្បិចសុំចូលបំរើរាជ ការខ្មែរតាម សម្តេចចៅពញា ស៊ួ។ ស៊ួ ស្នើទៅ ចៅហ្វា ម៉ូ តែដំបូង ចៅហ្វា ម៉ូ គ្មានការទុកចិត្តសោះឡើយ ព្រោះថា ខ្លួន និង បែន ធ្លាប់មានជម្លោះនឹង គ្នា តែ ស៊ួ រៀបរាប់នឹងបង្ហាញ ភស្តុតាង គ្រប់គ្រាន់ថា បែន រត់ពីស្រុក សៀម ព្រោះ សៀមចិត្តអាក្រក់ វាវាយខ្នង ចៀរស្លឹកត្រចៀក របស់គាត់។ ឃើញថា រឿងដែល ស៊ួ និយាយប្រាប់ទាំងប៉ុន្មាន ជាការពិត ស៊ួ ក៏សុខចិត្ត ទទួល បែន ឲធ្វើការជាមួយ។ ក្រោយមក ស៊ួ និង បែន រៀបចំ ផែនការ សម្លាប់ ម៉ូ នៅពេលភោជហារមួយ។ នៅពេលនោះ ស្នងគ្របក្ស ពញាស៊ួ និង

*(note de bas de page - suite)*

ស្ត្រី ព្រោះស្លាប់ក្នុងសង្គ្រាម ឬត្រូវរាជការខ្មែរ សម្លាប់ ព្រោះចោទថា ជាជនក្បត់ជាតិ ហើយបានជាជាប់ពាក្យថា កាលរាជ្យចៅហ្វាបែន មេម៉ាយ ១០ស្លាពុក១, ក្រមុំ ១០ មួយស្លឹក (ថ្លៃមួយស្លឹក) ។

ព្រះអង្គដួង សោយរាជ្យលើកទឹកដីខ្មែរ រួចតូច ព្រោះសៀម និង យួន គេកាត់យក ធ្វើជាទឹកដីរបស់គេ ហើយ ប្រជាពលរដ្ឋ ក៏មានចំនួនតិចតួចណាស់ ដែលនាំឲ រាជការ បាត់បង់ពន្ធដារ សំរាប់ទ្រទ្រង់រដ្ឋ និង រាជសក្តិ។ ស្រុកខ្មែរ សម្លប, ខ្លបខ្លាចបរទេស ហើយ គ្មានទស្សនវិស័យ នៃអនាគតច្បាស់លាស់។ ប្រជាពលរដ្ឋ រស់នៅក្នុង ភាពល្ងង់ខ្លៅ លែងមានការទុកចិត្តលើខ្លួនឯង និង អ្នកដឹកនាំជាតិផង ព្រោះខ្លួន គ្មានមានអ្វី ទុកជាការពឹងផ្អែក នៅសល់តែ ព្រះពុទ្ធសាសនា ជាជំនឿ យកមកអនុវត្ត សំរាប់តែស្វែងរកបុណ្យ ក្នុងជាតិខាងមុខ។ អ្វីដែលកំពុងរស់នៅក្នុងបច្ចុប្បន្នកាល ទុកជាកម្មផល ដែលខ្លួនត្រូវទទួលដាច់ខាត ជាបុណ្យ ឬ បាប ដែលខ្លួនបានកសាងកាលពី

យមរាជបែន ៣០នាក់ បានសម្លាប់ ស្នូគ្របក្ស ចៅហ្វា ម៉ូ ដេរដាស់ តែ ម៉ូ រត់រួច ទៅពួននៅស្រុកបាសាក់។ ចៅហ្វាយខែត្រខ្មែរ ដឹងដំណឹងនេះ ភ័យខ្លាចមានទោស ចោទថាក្បត់នឹង ពួកអ្នកកាន់អំណាចថ្មី នៅក្រុងឧដុង្គ ក៏ នាំសេនា ទៅចាប់ខ្លួន ម៉ូ បាន ហើយឲនាំមកក្រុងឧដុង្គជាប្រញាប់។ ខណៈនោះ ពញា ស៊ូ និង យមរាជ បែន ក៏បញ្ជាឲប្រហារជីវិត ចៅហ្វាម៉ូ ទៅ។ បន្ទាប់ ស៊ូ មានផែនការ លួចសម្លាប់ បែន ព្រោះ មានបំណង ចង់កាន់អំណាចតែម្នាក់ឯង។ តែ ការសម្ងាត់នេះ មានលេចឮដល់ បែន។ បែន បានចាត់សេនា មានថ្វីដៃ ៨នាក់ ទៅសម្លាប់ ពញា ស៊ូ និង ក្រុមគ្រួសារ អស់គ្មានសល់។ រួចហើយ បែន ក៏តាំងខ្លួន ជា សម្តេចចៅហ្វាទឡ្ហៈ សម្រេចរាជការក្រុងកម្ពុជា ក្នុង ឋានៈ ជា រាជានិសិទ្ធិ។

អតិតជាតិ។ ពួកអ្នកចេះដឹង មាននៅសល់ តិចតួចបំផុត ព្រោះត្រូវសៀម គេកេណ្ឌយកទៅស្រុកគេ ឬ មួយស្លាប់ ព្រោះរងគ្រោះនៅក្នុង ជម្លោះរវាងស្តេចទាំងឡាយ ឬសង្គ្រាម។ ថ្នាក់អ្នកដឹកនាំជាតិរួញខ្លួនដោយខ្លាច អំណាចស្តេចសៀម និង យួន ព្រោះឃើញ ព្រះមហាក្សត្រខ្លួន ក្លាយជាស្តេចចំណុះគេ។ សភាវគតិ នៃ ការយករួចខ្លួន ក្តាប់ចិត្ត សេនាមន្ត្រីខ្មែរបាន ដែលនាំឲ្យគ្មានការទទួលខុសត្រូវនៅក្នុងកិច្ចការ របស់ខ្លួន។ ដើម្បី បានសុខ ឬ ទទួលយសសក្តិ គឺយកការបញ្ជោរស្តេច ឬចៅហ្វាយធំ ជា មធ្យោបាយរស់នៅ។ វិការភាគជាទូទៅ នោះឯង (cette dégradation généralisée) ជា ទុព្វលភាព របស់ព្រះអង្គដួង។ ទ្រង់ឡើងគ្រងរាជសម្បត្តិ ជាមួយនឹង វិការភាគនោះ ទោះបីព្រះអង្គចង់ ឬ មិនចង់ក្តី ព្រោះ វាជា ស្ថានភាពពិត នៃស្រុកខ្មែរ ដែលបានធ្លាក់ចុះទៅក្នុង អត្តង្គត ច្រើនសតវត្សរួចមកហើយ ព្រោះ ថ្នាក់ដឹងនាំជាតិ ឬ នយជន (les politiques) គ្រប់ជំនាន់មុនៗ ប្រព្រឹត្តឆ្គោយ កែមិនរួចនូវនយោបាយដឹកនាំ របស់ខ្លួន។ ព្រះអង្គដួង យល់ដឹងច្បាស់ អំពី ស្ថានភាពនោះ ទ្រង់មានឆន្ទៈ នឹង រៀបចំរដ្ឋឡើងវិញ ដើម្បី លើកបញ្ឈរវិញព្រះនគរ។ តែ ការរៀបចំឡើងវិញ របស់ព្រះអង្គ គ្រាន់តែមានរូបភាពជា ការទិបមាសឡើងវិញ នៃ ព្រះសង្ហារ របស់ព្រះអង្គ (redorer son blason) តែប៉ុណ្ណោះ។ ព្រះអង្គ មិនបាន កែទម្រង់ជា

ជម្រៅ នូវ វចនាសម្ព័ន្ធ និង មានសិកភាព (ចិត្តគំនិត) នៃ ប្រព័ន្ធដឹកនាំជាតិនោះឡើយ។ ជម្ងឺ ស្រុកខ្មែរ នៅពេលនោះ មិនត្រឹមតែ ជាជម្ងឺ នូវការដឹកនាំជាតិ, សង្គមជាតិនោះទេ គឺ វាជាជម្ងឺ នៃ ការវិវត្តន៍ នៃ អារិយធម៌ជាតិតែម្តង គឺថា អារិយធម៌ណាមួយ ដែលមិនអាចដោះស្រាយនូវបញ្ហាកើតមានឡើង ក្នុងដំណើរ នៃការវិវត្តន៍ របស់ខ្លួន ជា អារិយធម៌អត្តង្គត។ អារិយធម៌ណាមួយ យកជម្រើស នូវការបិទភ្នែក មិនព្រមមើល នូវបញ្ហាធំៗ របស់ខ្លួន ជា អារិយធម៌ កំពុងមានជម្ងឺជាទម្ងន់។ អារិយធម៌ណាមួយ ធ្វើពុតនឹង គោលការណ៍គ្រិះ របស់ខ្លួន ជា អារិយធម៌ កំពុងស្លាប់។ ស្រុកខ្មែរ មិនត្រឹមតែ ជួបប្រទះ នូវវិបត្តិ នៃ អារិយធម៌ នោះឡើយ ថែមទាំង មាន បញ្ហា អណានិគម សៀម និងយួន ដែលនាំឲ ស្រុកខ្មែរបាត់អធិបតេយ្យជាតិ។ ព្រះអង្គដួង ទ្រង់មាន គោលបំណងទៅពឹងបារាំង ដើម្បី ដោះស្រាយ បញ្ហា ខ្មែរ នឹង សៀមយួន តែព្រះអង្គ មិនបានយល់ច្បាស់អំពី ចិត្តគំនិតអាណានិគមបារាំង។ យើងដឹងថា អពមង្គល ជាទូទៅ នៃរូបធាតុអាណានិគម គឺជា ការបោកបញ្ឆោត ដោយសុទ្ធចិត្ត ជាការលាក់ពុតរួម ប្រកបដោយប្រតិពល តាមការចោទជាសំនួរ នៃ បញ្ហា ឥតត្រឹមត្រូវ ដើម្បី អាចឆ្លើយតម្រូវនឹង ដំណោះស្រាយ ដ៏អាក្រក់បំផុត ដែលគេទុកជាដំណោះស្រាយ ស្របនឹងនាកាលនោះ របស់ប្រទេសអាណា

និគម ដែលមានគំនិតថា ប្រទេសអាណានិគម ជាប្រទេស មានអារិយធម៌ ដែលគេលែងប្រើបាន សំរាប់កសាងសង្គមទំនើប។

ចម្លើយ ដែលយើងឮ បែបជា បរិសុទ្ធចិត្ត ប្រកបដោយគ្រោះថ្នាក់បែបនេះឯង ដែលនាំឲយើង ពិនិត្យ ឲបានច្បាស់លាស់ ហើយចោទជាសំនួរថា អ្វីទៅជា គោលការណ៏ នៃ អាណានិគមនិយម ? ជាការព្រមព្រៀងគ្នាថា វាគ្មានមានចំណុចណាមួយ ដូចគេនិយាយថាជា ការផ្សាយសាសនា, សេចក្ដីស្រឡាញ់ នៃមនុស្សជាតិ, ការបន្ថយព្រំដែន នៃ ភាពខ្លៅ ជម្ងឺ ប្រជាហិង្សា, ការពង្រីក នៃ អាទិទេព, វិបុលកម្ម នៃ ច្បាប់ សោះឡើយ។ តែគួរយល់ព្រមគ្នាឲស្រេចតែម្ដង ដោយឆន្ទៈគ្មានច្រឡំថា វាជា អំពើ ផ្សងព្រេង និង ចោរប្លន់ នៃ ឈ្មួញធំគ្រឿងសម្ល, នាវាវីចារី, អ្នកស្វែងរកមាស់ និង ពួកពាណិជ្ជវិស័យ លោភា និង ប្រើកម្លាំងគ្រប់បែបយ៉ាង តែនៅ ក្រោយស្រមោលទាំងនោះនាំគ្នាទូលនូវ ទម្រង អារិយធម៌ចង្រៃ ក្នុងសម័យកាលមួយ នៃប្រវត្តិសាស្ត្រពិភពលោក ដែលជាសម័យ នៃ ការប្រណាំងប្រជែង នៃសេដ្ឋកិច្ច បដិបក្ខ៊។

ត្រូវដឹងថា ពួកអ្នកផ្សងព្រេង និង ចោរប្លន់ ទាំងនោះពាក់ឯកសណ្ឋាន ជាអ្នកធ្វើសង្គ្រាម ប្រដាប់អាវុធ គ្មានឧត្តមគតិអ្វីក្រៅពី សម្លាប់ ប្លន់ ប្រកដដោយ លោភា មុន

មកដល់ នៃ ពួកផ្សាយសាសនាគ្រិស្ត ទុកខ្លួនជាអ្នកប្រដៅដល់អ្នកដទៃទៀត ហើយនាំគ្នា បង្កើត នូវ សមិការអាក្រក់មួយ គឺ គ្រិស្តនិយម = អារិយធម៌; សៃយសាសន៍និយម = អំពើព្រៃផ្សៃ ដែលជាកម្មវិបាក នៃ អាណានិគមនិយម និង ការប្រកាន់ពូជសាសន៍ ដែល អ្នកទទួលរងគ្រោះ គឺ ជនអាណានិគម ទាំងឡាយ នៅក្នុងពិភពលោក។ គំនិតដែលបានរៀបរាប់ ខាងលើនេះហើយ ដែលបារាំង គេយកមក អនុវត្តនៅស្រុកខ្មែរ។ ដំណោះស្រាយណា ដែលពឹងបរទេស ជាដំណោះស្រាយ គ្មានមូលដ្ឋាននូវកម្លាំងជាតិនោះឡើយ ដូច្នេះវាមិនអាចគង់វង់នោះឡើយ ដូច្នេះ ផែនការ របស់ព្រះអង្គដួង យក បរទេស ជាជំនួយដើម្បីដោះស្រាយបញ្ហាបរទេសមួយទៀត វាគ្រាន់តែ ជាការបន្ត នូវគំនិត របស់ នយជនខ្មែរ ពីជំនាន់មុនៗតែប៉ុណ្ណោះ គឺ នាំគ្នាទៅពឹងសៀម ជួយច្បាំងនឹងយួន ឬ ក៏ដូចជាផ្ទុយទៅវិញ។

ព្រះអង្គដួង ទោះបីទ្រង់មាន ឆន្ទៈល្អយ៉ាងណា ចង់បង្ស្រព្រះនគរឡើងវិញយ៉ាងណាក៏ដោយ តែទ្រង់ រស់នៅក្នុងប្រព័ន្ធគំនិតចាស់ជ្រែះ ដែលនាំឲ្យទ្រង់ មិនអាចមាន ទំហំនៃគំនិតជាពន្លឺ ទូលំទូលាយ សំរាប់ដោះស្រាយបញ្ហាជាតិគរាប់សតវត្សមកហើយ។ ការណ៏នេះហើយ ជា បញ្ហា របស់

នយជនខ្មែរ រហូតមកដល់បច្ចុប្បន្ន និង ប្រជាពលរដ្ឋខ្មែរ រស់បន្ត នៅក្នុងវិបត្តិ អារិយធម៌ របស់ខ្លួន។

# ឯកសារ ភ្ជាប់

## ខ្សែញាតិវង្ស នៃ ព្រះបាទអង្គអេង

**អង្គអេង**

ស្តេចទ្រង់រាជ្យ

(១៧៧៩-១៧៩៦)

(រាជបុត្រា)

**អង្គចន្ទ** អង្គភិម អង្គស្ងួន អង្គអិម **អង្គដួង**

| អង្គចន្ទ | អង្គដួង |
|---|---|
| ស្តេចទ្រង់រាជ្យ | ស្តេចទ្រង់រាជ្យ |
| (១៨០៦-១៨៣៤) | (១៨៤១-១៨៦០) |
| រាជបុត្រី | រាជបុត្រា |
| ព្រះអង្គក្សត្រី បែន, **មី**, ពៅ, ស្ងួន | នរោត្តម, ស៊ីសុវត្ថិ, ស៊ីវត្ថា |
| **ព្រះអង្គក្សត្រី មី** | |
| ស្តេចទ្រង់រាជ្យ | ស្តេចទ្រង់រាជ្យ |
| (១៨៣៤-១៨៤១) | (១៨៦០-១៩០៤)-(១៩០៤-១៩២៧) |

# ប្រវត្តិសង្ខេប នៃ រជ្ជកាលព្រះអង្គចន្ទទី២

**ព្រះអង្គចន្ទ** : ឬ អង្គចន្ទទី២ ត្រូវបានព្រះចៅសៀម ថ្វាយព្រះអង្គ ឲឡើងគ្រងរាជសម្បត្តិ បន្តពី ព្រះបិតា តែឲចៅហ្វា ប៉ុក កាន់នាទី ជាអ្នកសម្រេចកិច្ចការផែនដីសិន រហូតដល់ព្រះអង្គចន្ទ មានព្រះជន្មវឌ្ឍនាឡើង ព្រោះ ព្រះអង្គនៅ កុមារណាស់ (៦ឆ្នាំ)។ ទទួលដំណឹង ពីព្រះចៅសៀម កាលណា ចៅហ្វា ប៉ុក បានកោះប្រជុំព្រះរាជវង្សានុវង្ស និង សេនាមន្ត្រីទាំងឡាយ ហើយ អញ្ជើញ ព្រះចន្ទ ឲស្តេចឡើងគ្រងរាជសម្បត្តិ តាមប្រពៃណី ព្រះនគរ។ បន្ទាប់មក ចៅហ្វា ប៉ុក ចាត់ឧកញ៉ាចក្រី កែប ឲនាំសេនាទាហាន ១ ម៉ឺននាក់ ទៅក្រុងទេពបុរី ជួយធ្វើសង្គ្រាមសៀម។ ក្រោយមកទៀត ចៅហ្វា ប៉ុក ចាត់ ឧកញ៉ាវាំង ឡុង ឲនាំសេនាទាហានខ្មែរ ប្រាំពាន់នាក់ លើកទៅជួយច្បាំង ស្តេចយួន ប្រឆាំងនឹង ពួកតៃសឺន នៅស្រុកយួន រហូតទទួលបានជ័យជំនះ។ ថ្ងៃក្រោយមក ចៅហ្វាប៉ុក អញ្ជើញ ព្រះអង្គចន្ទ ទៅក្រុងទេពបុរី ដើម្បីចូលថ្វាយបង្គំគាល់ ស្តេចសៀម ព្រះនាម ព្រះពុទ្ធយ៉តហ្វាចូឡាលោក។ នៅស្រុកសៀម ចៅហ្វាប៉ុក មានជម្ងឺជាទម្ងន់ ក៏ទទួលមរណភាព។ ស្តេចសៀម ទ្រង់ជឿតាំង ប្អូនចៅហ្វាប៉ុក នាម កាន់ ជា សម្តេចចៅហ្វាទឡ្ហៈ ជំនួយ សព ចៅហ្វាប៉ុក ហើយ ព្រះអង្គ ឲរៀបចំពិធីរាជាភិសេក ព្រះអង្គចន្ទ ជាមហាក្សត្រក្រុងកម្ពុជា នៅក្នុង ព្រះជន្ម ១៦ ឆ្នាំ។ បន្ទាប់មក ព្រះអង្គចន្ទ ក៏ថ្វាយបង្គំ

លាស្តេចសៀម មកស្រុកខ្មែរវិញ។ នៅឆ្នាំ ១៨០៩ ព្រះចៅព្រះពុទ្ធយ៉តហ្វាចូឡាលោក ទ្រង់សុគត។ ព្រះរាជបុត្រច្បងឡើងសោយរាជសម្បត្តិ តពីព្រះរាជបិតា ទ្រង់ ព្រះនាម ព្រះពុទ្ធឡឺតឡានភាល័យ។ ស្តេចសៀមថ្មីនេះ បានតាំង ព្រះអង្គស្ងួន ជា មហាឧភយោរាជ និង ព្រះអង្គអិម ជា មហាឧរាជ នៃ ក្រុងកម្ពុជា។ ស្តេចខ្មែរទាំងពីរអង្គ ថ្វាយបង្គំលាស្តេចសៀម ត្រឡប់មកស្រុកខ្មែរវិញ។ ក្រោយមក ព្រះអង្គចន្ទ ទ្រង់ឲចាប់ ឧកញ៉ាក្រឡាហោម មឿង និង ឧកញ៉ាចក្រី កែប នាំទៅប្រហារជីវិត ដោយចោទប្រកាន់ទោសថាមានបំណងចង់ក្បត់នឹងព្រះអង្គ។ ដំណឹងនេះ ឮដល់គ្រប់ខែត្រ នាំឲ ឧកញ៉ាតេជោ ម៉ឹង ចៅហ្វាយខែត្រ កំពង់ស្វាយ មានការបារម្ភនឹង សុវត្ថិភាព របស់ខ្លួន ព្រោះខ្លួនជាបក្សពួកនឹង ជនទាំងពីរនោះ ក៏រៀបចំកេណ្ឌរាស្រ្តមកប្រជុំទ័ព សំរាប់ការពារខ្លួនជាទុកជាមុន។ ដំណឹងឮដល់ព្រះអង្គចន្ទ ទ្រង់ខ្ញាល់ណាស់ ទ្រង់ត្រាស់ឲលើកទ័ពទៅចោមចាប់ ឧកញ៉ាតេជោ ម៉ឹង តែ ម៉ឹង ពុំហ៊ានទទួលច្បាំងក៏នាំ ប្រពន្ធកូន រត់ទៅស្រុកសៀម។ ក្រោយមក នៅស្រុកខ្មែរ មានឃើញផ្កាយដុះកន្ទុយ ចាក់ទៅទិសពាយ័ព្យ។ វេលានោះ ព្រះអង្គស្ងួន ជា មហាឧភយោរាជ កើតបណ្តាប្រទ័យមិនចង់គង់ក្នុងក្រុង ជាមួយ ព្រះអង្គចន្ទ ជាព្រះរៀម ក៏នាំបណ្តារាស្រ្តជាខ្ញុំរាជការ រត់ចេញពីទីក្រុងទាំងយប់។ ទៅដល់ខែត្រពោធិសាត់ ចៅហ្វាយខែត្រ នាម ឧកញ៉ាសួគ៌ា

ប៉ុក ក៏ទទួល ហើយ អញ្ជើញស្តេច គង់នៅទីនោះ។ ព្រះអង្គ ជ្រាបថា ព្រះអនុជ ភៀសខ្លួន ទៅនៅ ខែត្រពោធិសាត់ ក៏ ប្រើមន្ត្រីទៅអញ្ជើញជាច្រើនដង ឲវិលត្រឡប់មកវិញ តែ ព្រះអង្គស្ងួន មិនព្រមជាដាច់ខាត។ ហ្លួងចន្ទ មានព្រះទ័យថា ច្បាស់ជាស្រុកនឹង កើតសង្គ្រាម ជាពុំខាន ជាមួយ នឹងព្រះអនុជ។ ដូច្នេះ ព្រះអង្គ សម្រេចទៅសុំទ័ពស្តេចយួន យ៉ាឡុង មកបម្រុងប្រការ។ ឯព្រះចៅសៀម ទ្រង់ ជ្រាបថា ព្រះអង្គចន្ទ ទៅចងមេត្រីនឹងយួនវិញ, ទ្រង់ក៏ ចាត់មេទ័ពសៀម ឲលើកទ័ពចេញមកជួបនឹង ព្រះអង្គ ស្ងួន ដើម្បី ជួយស្តេចនេះ ច្បាំងនឹងយួន។ មានជំនួយពី សៀម ព្រះអង្គស្ងួន មានព្រះទ័យចង់ប្រកួតព្រះចេស្ដានឹង ព្រះរៀម ហើយត្រាស់ប្រើមន្ត្រីព្រះអង្គ ឲមកក្រាប ថ្វាយបង្គំទូល ព្រះអង្គចន្ទ សុំខែត្រ ក្រគរ និង ខ្លុង ជា សម្បត្តិផ្ទាល់។ ព្រះអង្គចន្ទ ទ្រង់ព្រះរាជទានតាមសុំ ដើម្បី វៀរចាកសង្គ្រាម។

ក្រោយមក ស្តេចសៀម ត្រាស់ឲលើកទ័ព មានសេនា ទាហាន ៥ពាន់នាក់ មកស្រុកបាត់ដំបង មួយកង និង ផ្លូវស្ទឹងត្រែង មួយកងទៀត។ ព្រះអង្គចន្ទ ទ្រង់ព្រួយព្រះទ័យក្រៃពេក ទ្រង់ចាត់មេទ័ពខ្មែរ ឲនាំទ័ព មានសេនា ទាហាន ១ពាន់នាក់ ទៅឈរប្រចាំគយល្បាត នៅដំបន់ បរិវេណ ឈើនាគ ក្នុងខែត្រ រលាប្អៀរ និង ខែត្រកំពង់

ឆ្នាំ។ ក្រោយមកទៀត សៀម លើកទ័ពជើងទឹក និង ជើងគោក បន្ថែមទៀត មកស្រុកខ្មែរ។ នៅឆ្នាំ ១៨១២ ទ័ពសៀម និង ទ័ពហ្លួងខ្មែរ ជួបច្បាំងគ្នា។ ទ័ពហ្លួងខ្មែរ ទ្រាំពុំបាន ក៏ថយបណ្ដើរ ច្បាំងបណ្ដើរ ហើយឲនាំសារថ្វាយ ព្រះអង្គចន្ទ ឲទ្រង់ជ្រាបជាប្រញាប់។ ស្ដេចទ្រង់ជ្រាបហើយ ក៏នាំ ព្រះរាជវង្សានុវង្ស ចេញដំណើរ ទៅស្រុកក្រោម ដោយ មានទ័ពយួន បានហែស្ដេចផង។ ក្រោយមក ព្រះអង្គអិម និង ព្រះអង្គដួង នាំគ្នារត់ចោលព្រះអង្គចន្ទ ទៅស្រុក សៀម ដោយមិនព្រមនឹងព្រះរៀម ទៅចងមេត្រីនឹងយួន ក្បត់សៀម។ ព្រះដឹងដំណឹងថា ព្រះអនុជពីរព្រះអង្គ គេច វេះរត់ចៀសព្រះអង្គ ស្ដេចក៏សម្រេចព្រះទ័យ ចេញព្រះទីនាំង នាវា សំដៅទៅស្រុកយួនតែម្ដង។ ស្ដេចយួន យ៉ាឡុង សន្យាជួយទំនុកបម្រុងព្រះអង្គ មិនឲដាច់មេត្រីទេ។ រីឯ ព្រះអង្គអិម និង ដួង យាងមកដល់ ក្រុងឧដុង្គ បានជួប ជុំនឹងព្រះអង្គស្ងួន[13] ហើយ ស្ដេចទាំងបីអង្គ ក៏សម្រេចព្រះ ទ័យ ទៅស្រុកសៀម ទុកសេនាទហាន ខ្មែរ-សោះម ឲនៅ ចាំរក្សា ព្រះបរមរាជវាំងបន្ទាយពេជ្យ ចូលថ្វាយបង្គំព្រះ ចៅសៀម ដើម្បី ទូលថ្វាយ ពីស្ថាភាពនៅស្រុកខ្មែរ។ ចំណែក ស្ដេចយួន ចាត់មេទ័ព ឲរៀបក្បួនទ័ព មាន ទាហានចំនួន ១ម៉ឺននាក់ផ្លាយ ហែព្រះអង្គចន្ទ ចូលស្រុក

[13] ព្រះអង្គស្ងួន ទ្រង់ឈឺជាទម្ងន់ ហើយ សុគត នៅក្រុងទេពបុរី ស្រីអយុធ្យា ក្នុងព្រះជន្ម ២៩ ឆ្នាំ។

ខ្មែរវិញ។ មកដល់ផែកំពង់លួង ព្រះចន្ទ បានជួបមន្ត្រីខ្មែរ មួយចំនួន នៅទីនោះ ដែលធ្លាប់បានហែព្រះអនុជ ទាំងបីអង្គ ទៅស្រុកសៀម តែ មិនបានបន្តដំណើរ ហើយមិនទាន់បាន ត្រឡប់មក ក្រុងឧដុង្គវិញ។ បន្ទាប់អ្នកទាំងនោះ ក៏នាំគ្នាហែព្រះអង្គចន្ទ មកក្រុងឧដុង្គ។ ទ័ព ខ្មែរ-សៀម ចាំរក្សាបន្ទាយពេជ្យ ក៏ថយទ័ព តាមផ្លូវសន្តិភាព ត្រឡប់ទៅស្រុកបាត់ដំបង។ ក្រោយមក ព្រះអង្គចន្ទ ទ្រង់ចាត់មន្ត្រីទូត នាំ ព្រះរាជសារ និង រាជបណ្ណាការ ទៅថ្វាយស្តេចសៀម សុំចងមេត្រីជាថ្មី។ ស្តេចសៀម ទ្រង់មានព្រះទ័យអំណរពនប្រមាណ។ មិនយូរប៉ុន្មាន ស្តេចយួន ត្រាស់ប្រើមេទ័ពយួន ឲនាំទ័ព ៣ពាន់នាក់ មកឈរនៅខែត្រត្រពាំង, ១ពាននាក់ មកធ្វើបន្ទាយនៅខែត្រមាត់ជ្រូក ហើយជីកព្រែកកាត់ចេញទៅមាត់សមុទ្រ ត្រូវខែត្រ ពាម ចម្ងាយ ១៣២៥ ស៊ីន, ជីកពីមាត់ជ្រូក ទៅដល់នឹងទន្លេខាងកើត ចម្ងាយផ្លូវ ៣៤២ ស៊ីន ១២ ព្យាម។ ថ្ងៃក្រោយមក ចៅហ្វាយខែត្រពោធិសាត់ នាម កោះ និង សម្តេចចៅពញា សួស មានជម្លោះនឹងគ្នា។ ឧកញ៉ា កោះ ក៏នាំប្រពន្ធកូន ថែមទាំង កៀរគ្រួ ខែត្រពោធិសាត់ ២ភាគ៣ នាំរត់ទៅស្រុកសៀម ចូលក្រាបបង្គំទូល ព្រះពុទ្ធឡឹតឡា គ្រប់សេចក្តី ពី ការចោទប្រកាន់ពី សម្តេចសួស ថាខ្លួនមិនសុចរិទ្ធ ចំពោះហ្លួងចន្ទ។ ព្រះអង្គចន្ទ ជ្រាបរឿងនេះ ទ្រង់ មានព្រះទ័យព្រួយក្រៃណាស់ ព្រោះច្បាស់ជាស្រុកនឹង

មានសង្គ្រាមជាពុំខាន។ ព្រះអង្គតែតាំង ឧកញ៉ា យស ៤ ចេញទៅឈររក្សាខែត្រពោធិសាត់ និង ឧកញ៉ាឡូង ជាមេទ័ព នាំសេនាទាហាន ២ពាន់នាក់ ទៅការពារខែត្រ។ ក្រោយពីនោះ ស្ថានការ ក៏រាបទាបសុខសប្បាយវិញ ទ្រង់គ្រាស់បង្គាំ៤ ឧកញ៉ាឡូងរំសាយទ័ព ហើយ វិលត្រឡប់មកក្រុងឧដុង្គវិញ។ តែមិនយូរប៉ុន្មាន មានដំណឹងថា សៀមលើកទ័ព ជាច្រើន មកដល់ខែត្របាត់ដំបង មានទាំងទ័ពជើងទឹក ថែមទៀត។ ព្រះអង្គចន្ទ តែងតាំង សម្តេចចៅហ្វា ឆាន់ ធ្វើ ជាមេទ័ពចម នាំសេនាទាហាន លើកទៅតទល់នឹងទ័ពសៀម។ ឧកញ៉ា ឡូង ត្រូវបាន តែងតាំងជានាយក ហ្វឹងហ្វឺនយោធិន។ មេទ័ព ដទៃទៀត នាម ពេជ្យ, ម៉ី និង មាស នាំទ័ពស្រួច ទៅទទួលច្បាំងនឹងសៀមភ្លាម។ តែដោយសារ ការកេណ្ឌរាស្ត្រ ធ្វើទាហាន មានការយឺតយូរមិនទាន់ពេល, ឧកញ៉ាទាំង៤ ក៏នាំទាហាន ផ្ទាល់របស់ខ្លួន ៨០នាក់ និង ទាហានថ្មី ៣០០ ទៅមុនសិន ឆ្លងខែត្រលង្វែក ហើយរង់ចាំ ទព័ធំ នៅខែត្ររលាប្អៀរ តែមិនឃើញ បញ្ជូនមកសោះ។ ពេលទ័ពសៀម លើកមកដល់ឧកញ៉ាទាំងបួន ក៏ទទួលច្បាំងនឹងសៀម តែចំនួនទាហានតិចពេក ក៏ទទួលបរាជ័យទៅ។ ទ័ពសៀមចាប់បាន ឧកញ៉ាម៉ីយកទៅ តែពុំសម្លាប់ទេ។ ឧកញ៉ាឡូង រត់បែបពីទ័ព ជាមួយក្មួយ៣នាក់ ទៅខែត្របាភ្នំ។ ឧកញ៉ាមាស រត់ចូលមកក្រុងឧដុង្គ ហើយក្រាបបង្គំទូលព្រះអង្គ

ចន្ទ គ្រប់ប្រការ។ ក្រោយនិ្ទចមក ព្រះអង្គចន្ទ នាំ ព្រះរាជវង្សានុវង្ស ចេញដំណើរតាមផ្លូវទឹក ទៅស្រុកយួន។ ទ្រង់ប្រថាប់នៅស្រុកលុងហោ។ ឯបញា បឌិនតេជោ មេទ័ពសៀម នាំ ព្រះអង្គអិម និង ដួង ចូលគង់ ក្នុងព្រះបរមរាជវាំងឧដុង្គ។ មេទ័ពសៀម បញ្ជាឲសេនាទាហាន លើកទៅវាយបន្ទាយយួន នៅខែត្រមាត់ជ្រូក។ រីឯ ឧកញ៉ា ឡុង បេលមកដល់ខែត្របាភ្នំ បង្គាប់ឲចៅហ្វាយខែត្រ នាម ហ៊ូ កេណ្ឌរាស្ត្របាន ១ពាន់នាក់ បញ្ចូលក្នុងកងទ័ព។ ចំណែកទ័ពសៀម លើកមកច្រើនផ្លូវ មកដល់ខែត្រព្រៃវែង ប្រទះនឹងទ័ព ឧកញ៉ាឡុង និង ហ៊ូ ច្បាំងគ្នានៅទីនោះ។ ទ័ពសៀមបរាជ័យ ដកថយ មកដល់ភូមិតុរី រុះរើផ្ទះអ្នកស្រុកដែលរត់ចោលភូមិ ចងជាក្បូន រួចចំឡងទ័ព ទៅដាក់ខាតត្រើយ រកាកោង។ ខណៈនោះ បណ្ដារាស្ត្រ ខឹងនឹងសៀម ប្រជុំគ្នាតាំងជាស្ម័គ្របក្សពួកជាទ័ព លើកទៅដេញកាប់សៀម ស្លាប់អស់ជាច្រើន ហើយ ទ័ពសៀម បែករត់ខ្ចាត់ខ្ចាយអស់។ ទ័ពសៀមមួយខ្សែទៀត លើកទៅវាយបន្ទាយយួន នៅ ពាមនាវ ទទួលបានជ័យជំនះ ដេញទ័ពយួន រត់ទៅដល់ លុងហោ។ តែគ្រប់សមរភូមិ ទ័ពសៀមច្បាំងចាញ់យួន។ ពញាបឌិតេជោ មេទ័ពសៀម និងឧកញ៉ាសួគ៌ាកោះ មេទ័ពខ្មែរ ក៏ដកថយទៅឈរនៅខែត្របាត់ដំបង។ ក្រោយពីវាយបន្ទាយយួនបែក នៅពាម មេទ័ពសៀម នាំទ័ពចុះទូកសមុទ្រ ឆ្លងទៅស្រុកសៀម។ រីឯ

ព្រះអង្គអិម និង ដួង ព្រមទាំង ឧកញ៉ា ម៉ា ដឹកដំណឹងគ្រប់ប្រការ ក៏ដកថយទ័ព តាមមាត់ទន្លេ រៀងទៅដល់កំពង់រទេះ រួចសំដៅទៅស្រុកសៀម។ ទ័ពយួន លើកមកដល់ភ្នំពេញ រីឯ ឧកញ៉ា ឡូង និង ហ៊ូ លើកទ័ពឆ្លងទៅបង្រ្កាបខែត្រកំពង់ស្វាយ។ នៅឆ្នាំ ១៨៣៤ ទ័ពយួន បានដង្ហែ ព្រះអង្គចន្ទ ពីស្រុកយួន ឡើងមកភ្នំពេញ។ ទ្រង់ចតព្រះទីនាំងនាវា នៅកំពង់កោះស្លាកែត រួចទ្រង់ត្រាស់ឲធ្វើព្រះរាជវាំង គង់នៅកោះនោះ។ សម្តេចចៅហ្វា ឆាន់ និង ពេញ សួស មានជម្ងឺឈឺដោយរោគ ក៏ធ្វើមរណភាពទៅ។ ក្រោយមក ព្រះអង្គចន្ទ មានអាពាធមូលជាទម្ងន់ ហើយសុគត នៅលើទីនាំនាវា ក្នុងព្រះជន្ម ៤៤ ឆ្នាំ។